**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# បេឡាជាតិរបបសន្តិសុខសង្គមៈ ហានិភ័យការងារ និងសុខភាពកម្មករនិយោជិត

ស្រាវជ្រាវពីថ្ងៃទី០៣ មេសា ២០១៧ ដល់ថ្ងៃទី៣១ ឧសភា ២០១៧


តាក់តែងឡើងដោយ                                   សាស្ត្រាចារ្យណែនាំ

និស្សិតឈ្មោះ៖ **ក. អ៊ិត ហ្សូលីនដា**          លោក **ម៉ៅ បុណ្ណា**

**ក. គីន ចាន់ស្រីរ័ត្ន**



ថ្នាក់បរិញ្ញាបត្រ *នីតិសាស្ត្រ*          ឆ្នាំចូលរៀន          ២០១៣

ជំនាន់ទី ១៧          ឆ្នាំសរសេរសារណា          ២០១៧

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# បេឡាជាតិរបបសន្តិសុខសង្គមៈ ហានិភ័យការងារ និងសុខភាពកម្មករនិយោជិត

ស្រាវជ្រាវពីថ្ងៃទី០៣ មេសា ២០១៧ ដល់ថ្ងៃទី៣១ ឧសភា ២០១៧


| តាក់តែងឡើងដោយ | | សាស្ត្រាចារ្យណែនាំ |
|---|---|---|
| និស្សិតឈ្មោះ | **ក. អ៊ិត ហ្សូលីនដា** | លោក **ម៉ៅ បុណ្ណា** |
| | **ក. គឹន ចាន់ស្រីរ័ត្ន** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ *នីតិសាស្ត្រ* | | ឆ្នាំចូលរៀន | ២០១៣ |
| ជំនាន់ទី ១៧ | | ឆ្នាំសរសេរសារណា | ២០១៧ |

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីរនាក់ឈ្មោះ អ៊ុត ហ្សូលីនដា និង ភឺន ចាន់ស្រីរ័ត្ន ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៧ (ក្រុម L4C4) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើសារណាបញ្ចប់ការសិក្សាស្តីពី បេឡាជាតិរបបសន្តិសុខសង្គមៈ ហានិភ័យការងារ និងការថែទាំសុខភាពកម្មករនិយោជិត មានកិត្តិយសសូមលំអោនកាយគោរពប្រណិបតន៍ សំដែងការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ៖

លោកឪពុក និងអ្នកម្តាយ ដែលអ្នកមានគុណទាំងពីរបានផ្តល់កំណើតឲ្យកូន ចិញ្ចឹម បីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់ធំ ព្រមទាំងទំនុកបម្រុងកូនសព្វសារពើទាំងអស់។ លោកទាំងពីរបានអប់រំ ណែនាំ និងប្រៀនប្រដៅកូនឲ្យចេះដឹងខុសត្រូវ ធ្វើជាមនុស្សល្អ ពលរដ្ឋល្អប្រកបដោយសីលធម៌ និងសុជីវធម៌ ដែលជាទីស្រលាញ់រាប់អាននៃអ្នកដទៃ។ លើសពីនេះទៀត លោកទាំងពីរបានបញ្ជូនកូនឲ្យចូលសាលារៀន ទំនុកបម្រុងទាំងផ្នែកស្មារតី និងសម្ភារៈតាំងពីមត្តេយ្យសិក្សារហូតដល់មហាវិទ្យាល័យ។ លោកទាំងពីរប្រៀបដូចជាម្លប់ដ៏ត្រជាក់សម្រាប់កូន ហើយកូនសូមថ្លែងអំណរគុណចំពោះ ការលើកទឹកចិត្ត ក្តីសង្ឃឹម ភាពជឿជាក់ និងការទំនុកបម្រុងកន្លងមក។ ចំពោះអ្វីដែលលោកទាំងពីរ បានផ្តល់ឲ្យ កូននឹងចងចាំគ្មានថ្ងៃបំភ្លេចបានឡើយ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំគ្រប់គ្រង ជ្រោមជ្រែង និងបង្ហាត់បង្រៀនយើងខ្ញុំឲ្យទទួលបានចំណេះដឹងយ៉ាងច្រើន។

លោកសាស្ត្រាចារ្យ ម៉ៅ បុណ្ណា (សាស្ត្រាចារ្យណែនាំ) ដែលលោកបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ព្រមទាំងចំណាយពេលវេលាផ្ទាល់ខ្លួន ក្នុងការជួយពន្យល់ណែនាំ ផ្តល់យោបល់ល្អៗ និងផ្តល់ឯកសារមួយចំនួន ព្រមទាំងកែតម្រូវយ៉ាងយកចិត្តទុកដាក់ រហូតដល់សារណាមួយនេះលេចចេញជារូបរាង។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរ សូមសម្តែងសេចក្តីគោរព និងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ជាពិសេសសូមប្រសិទ្ធិពរជ័យ សិរីមង្គល និងសូមបួងសួងវត្ថុស័ក្តិសិទ្ធិក្នុងលោកតាមជួយថែរក្សាអ្នកទាំងអស់ឲ្យជួបប្រទះតែសេចក្តីសុខ និងជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ចំណេះវិជ្ជា គឺជាកត្តាមួយដ៏សំខាន់សម្រាប់មនុស្សគ្រប់រូប ដើម្បីក្លាយខ្លួនជាបុគ្គលម្នាក់ដែលពោរពេញដោយចំណេះវិជ្ជា។ ការសិក្សាតែក្នុងថ្នាក់មួយមុខមិនទាន់គ្រប់គ្រាន់ទេ ពោលគឺទាមទារឲ្យមានការស្រាវជ្រាវបន្ថែមទៀត។ ហេតុដូចនេះហើយ បន្ទាប់ពីបានសិក្សាអស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរនាក់បានពិភាក្សាគ្នាហើយបានសម្រេចចិត្តធ្វើការស្រាវជ្រាវឯកសារ ក្នុងការសរសេរសារណាដើម្បីបញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនាចុងឆ្នាំ២០១៧ខាងមុខនេះ។

ការជ្រើសរើសប្រធានបទដើម្បីសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ពុំមានការដាក់កំហិតពីសាកលវិទ្យាល័យទេ ពោលគឺអាស្រ័យលើការជ្រើសរើសរបស់និស្សិតផ្ទាល់ ដោយមានការផ្ដល់ជាគោលគំនិតពីលោកសាស្ត្រាចារ្យ **ម៉ៅ ប៊ុណ្ណា**។ យើងខ្ញុំទាំងពីរបានជ្រើសរើសប្រធានបទមួយទាក់ទងនឹងស្ថាប័នសាធារណៈ ដែលមានចំណងជើងថា "**បេឡាជាតិរបបសន្តិសុខសង្គមៈ ហានិភ័យការងារ និងសុខភាពកម្មករនិយោជិត**"។ ការសិក្សាស្រាវជ្រាវ និងចងក្រងប្រធានបទសារណាមួយនេះ យើងខ្ញុំមានបំណងបីយ៉ាង ទីមួយគឺដើម្បីទុកជាឯកសារសម្រាប់មិត្តនិស្សិតអ្នកស្នេហាវិស័យច្បាប់ជំនាន់ក្រោយ និងជាឯកសារជំនួយសម្រាប់អ្នកស្ថិតក្នុងវិស័យដ៏ទៃទៀត។ គោលបំណងទីពីរ ដើម្បីបង្ហាញពីការវាស់ស្ទង់សមត្ថភាពរបស់ខ្លួនឯង បន្ទាប់ពីការសិក្សារយៈពេលបួនឆ្នាំកន្លងមក និងគោលបំណងទីបី គឺដើម្បីពង្រីកចំណេះដឹង និងស្គាល់ឲ្យកាន់តែច្បាស់ពីរបបសន្តិសុខសង្គមក្នុងប្រទេសកម្ពុជា។

ការចងក្រងសារណានេះឲ្យលេចចេញជារូបរាង គឺមិនមែនងាយស្រួលនោះទេ ពោលគឺយើងខ្ញុំទាំងពីរបានជួបប្រទះការលំបាកជាច្រើនក្នុងការស្វែងរកឯកសារ ដើម្បីសរសេរដោយទទួលបានការពន្យល់ណែនាំ និងកែតម្រូវយ៉ាងយកចិត្តទុកដាក់ពី លោកសាស្ត្រាចារ្យ **ម៉ៅ ប៊ុណ្ណា**។

ជាការពិតណាស់ឯកសារមួយនេះ មិនទាន់មានភាពល្អឥតខ្ចោះទេ ហើយយើងខ្ញុំនឹងរង់ចាំទទួលយកការរិះគន់ ដើម្បីស្ថាបនា និងកែលម្អរាល់កំហុសឆ្គងទាំងឡាយពីសំណាក់សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងឡាយ។ ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរ សូមបួងសួងវត្ថុស័ក្តសិទ្ធិទាំងឡាយតាមជួយថែរក្សាអ្នកមានគុណ លោកគ្រូ អ្នកគ្រូ និងកុលបុត្រកុលធីតាមខ្មែរគ្រប់រូបជួបប្រទះសេចក្ដីសុខគ្រប់ពេលវេលា។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........................................................ ១

## ជំពូកទី១

## ទិដ្ឋភាពទូទៅ និងការគ្រប់គ្រងហិរញ្ញវត្ថុនៃបេឡាជាតិរបបសន្តិសុខសង្គម

**១.១. ការរៀបចំ និងការប្រព្រឹត្តទៅនៃបេឡាជាតិរបបសន្តិសុខសង្គម** ........ ៤

**១.១.១. លក្ខណៈទូទៅនៃបេឡាជាតិរបបសន្តិសុខសង្គម** ........ ៤

**១.១.២. គោលបំណង និងតួនាទីរបស់បេឡាជាតិរបបសន្តិសុខសង្គម** ........ ៤

១.១.២.១. គោលបំណងបេឡាជាតិរបបសន្តិសុខសង្គម ........ ៤

១.១.២.២. ភារកិច្ចបេឡាជាតិរបបសន្តិសុខសង្គម ........ ៥

**១.១.៣. រដ្ឋបាលនៃបេឡាជាតិរបបសន្តិសុខសង្គម** ........ ៥

១.១.៣.១. ក្រុមប្រឹក្សាភិបាល ........ ៥

១.១.៣.២. អង្គការប្រតិបត្តិនៃបេឡាជាតិរបបសន្តិសុខសង្គម ........ ៦

**១.១.៤. របបធានារ៉ាប់រងក្នុងបេឡាជាតិរបបសន្តិសុខសង្គម** ........ ៧

**១.២. ការគ្រប់គ្រងហិរញ្ញវត្ថុ** ........ ៨

**១.២.១. កិច្ចការគណនេយ្យ** ........ ៨

**១.២.២. ប្រភពធនធាន** ........ ៩

**១.២.៣. ការចំណាយ** ........ ៩

## ជំពូកទី២

## របបធានារ៉ាប់រងហានិភ័យការងារនៃបេឡាជាតិរបបសន្តិសុខសង្គម

**២.១. ការចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម** ........ ១១

**២.១.១. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន** ........ ១២

២.១.១.១. លក្ខខណ្ឌទូទៅ ........ ១២

២.១.១.២. បែបបទនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ........ ១៣

២.១.១.៣. អត្តសញ្ញាណកម្មសហគ្រាស គ្រឹះស្ថាន ........ ១៤

**២.១.២. ការចុះបញ្ជិកាកម្មករនិយោជិត** ........ ១៤

២.១.២.១. ទម្រង់បញ្ជិកាកម្មករនិយោជិត ........ ១៤

២.១.២.២. អត្តសញ្ញាណកម្មនៃកម្មករនិយោជិត ............ ១៤
២.១.២.៣. របាយការណ៍ចំនួនកម្មករនិយោជិត ............ ១៥
**២.២. ការកំណត់អត្រាភាគទាន និងបែបបទបង់ភាគទានរបបហានិភ័យការងារ** ............ ១៥
**២.២.១. កាតព្វកិច្ចបង់ភាគទាន** ............ ១៥
**២.២.២. អត្រាភាគទានហានិភ័យការងារ** ............ ១៦
**២.២.៣. កាលបរិច្ឆេទបង់ភាគទាន** ............ ១៧
**២.២.៤. បែបបទបង់ភាគទាន** ............ ១៨
**៣.៣. តាវកាលិកហានិភ័យការងារ** ............ ១៨
**៣.៣.១. និយមន័យ** ............ ១៩
៣.៣.១.១. គ្រោះថ្នាក់ការងារ ............ ១៩
៣.៣.១.២. ពេលធ្វើដំណើរទៅកន្លែងការងារ ............ ១៩
៣.៣.១.៣. ជម្ងឺវិជ្ជាជីវៈ ............ ១៩
**៣.៣.២. ការទទួលបានតាវកាលិក** ............ ២០
៣.៣.២.១. សិទ្ធិទទួលបានតាវកាលិក ............ ២០
៣.៣.២.២. ការជូនដំណឹងហានិភ័យការងារ ............ ២១
៣.៣.២.៣. ការអង្កេតហានិភ័យការងារ ............ ២២
៣.៣.២.៤. តាវកាលិកហានិភ័យការងារដែលត្រូវផ្តល់ ............ ២២
**៣.៣.៣. ការទាមទារតាវកាលិក** ............ ៣២

## ជំពូកទី៣

## របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនៃបេឡាជាតិរបបសន្តិសុខសង្គម

**៣.១. វិសាលភាពនៃការអនុវត្ត និងការបង់ភាគទានផ្នែកថែទាំសុខភាព** ............ ៣៤
**៣.១.១. ដំណាក់កាលអនុវត្ត** ............ ៣៤
**៣.១.២. កាលបរិច្ឆេទអនុវត្ត** ............ ៣៥
**៣.១.៣. ការបង់ភាគទានថែទាំសុខភាព** ............ ៣៥
៣.១.៣.១. កាតព្វកិច្ចបង់ភាគទាន ............ ៣៥
៣.១.៣.២. អត្រាភាគទាន ............ ៣៦
៣.១.៣.៣. កាលបរិច្ឆេទបង់ភាគទាន ............ ៣៨
**៣.២. តាវកាលិកផ្នែកថែទាំសុខភាព** ............ ៣៩

**៣.២.១. កញ្ចប់តាវការលិកសុខភាព** ..................... ៣៩
៣.២.១.១. សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ..................... ៣៩
៣.២.១.២. សេវាបញ្ជូនអ្នកជម្ងឺឬ ជនរងគ្រោះ និងសេវាបញ្ជូនសព ..................... ៤១
៣.២.១.៣. ប្រាក់បំណាច់ប្រចាំថ្ងៃ ..................... ៤១
**៣.២.២. សេវាបន្ថារសុខភាព** ..................... ៤១
**៣.២.៣. លក្ខខណ្ឌទទួលបានសេវាថែទាំសុខភាព** ..................... ៤២
៣.២.៣.១. សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ..................... ៤២
៣.២.៣.២. លក្ខខណ្ឌទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ..................... ៤៣
**៣.២.៤. សិទ្ធិទទួលបានសេវាថែទាំសុខភាព** ..................... ៤៣
**៣.២.៥. ជម្ងឺរ៉ាំរ៉ៃ** ..................... ៤៤
**៣.២.៦. ករណីផ្សេងៗមិនរាប់បញ្ចូលក្នុងតាវការលិកសំណង** ..................... ៤៥
**៣.៣. ការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និង មូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាព** ..................... ៤៦
**៣.៣.១. ការចុះកិច្ចព្រមព្រៀង** ..................... ៤៦
**៣.៣.២. ការត្រួតពិនិត្យគុណភាពសេវា** ..................... ៤៦
**៣.៣.៣. ការទូទាត់ថ្លៃសេវាថែទាំសុខភាព** ..................... ៤៧
៣.៣.៣.១. យន្តការទូទាត់ថ្លៃសេវា ..................... ៤៧
៣.៣.៣.២. បែបបទទូទាត់ថ្លៃសេវាថែទាំសុខភាព ..................... ៤៨
៣.៣.៣.៣. ការបដិសេធទូទាត់ថ្លៃសេវា ..................... ៤៨
**សេចក្តីសន្និដ្ឋាន** ..................... ៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

សេដ្ឋកិច្ច ជាកត្តាមួយដ៏សំខាន់ដើម្បីជួយប្រទេសជាតិឲ្យមានភាពរីកចម្រើន។ សព្វថ្ងៃនេះ ដោយសារតែសន្ទុះដ៏លឿននៃសេដ្ឋកិច្ច បានធ្វើឲ្យបណ្តាប្រទេសជាច្រើននៅក្នុងពិភពលោកមានការប្រកួតប្រជែងគ្នាយ៉ាងខ្លាំង។ ដូច្នេះ ទើបបណ្តាលឲ្យមានក្រុមហ៊ុន រោងចក្រ សហគ្រាសតូច ធំ ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច។ កំណើននេះ បានធ្វើឲ្យការជួលកម្លាំងពលកម្មក្នុងវិស័យការងារមានសន្ទុះកើនឡើង ពោលគឺផ្តល់ទីផ្សារការងារយ៉ាងច្រើនជូនប្រជាពលរដ្ឋ។ សកម្មភាពនេះ បានបង្កើតឲ្យមានទំនាក់ទំនងគតិយុត្តរវាងអ្នកដែលជួលគេធ្វើការ ហៅថានិយោជក និងអ្នកធ្វើការឲ្យគេ ហៅថានិយោជិត ហើយត្រូវបានកំណត់នៅក្នុងនីតិមួយច្បាស់លាស់ដើម្បីចាកផុតពីរបបទាសករ។ ជាក់ស្តែងប្រទេសកម្ពុជា ក៏មានច្បាប់ការងារសម្រាប់គ្រប់គ្រងសកម្មភាពការងាររវាងនិយោជក និងកម្មករនិយោជិតឲ្យមានសមភាព ដោយមិនមានការរើសអើងក្នុងការបំពេញការងារ ឬការរំលោភបំពានសិទ្ធិគ្នាទៅវិញទៅមក និងធានាឲ្យបានការបំពេញការងារ ប្រកបដោយការយោគយល់អធ្យាស្រ័យឲ្យគ្នាទៅវិញទៅមក។ ច្បាប់ការងារនេះមានការវិវត្ត០៥ដំណាក់កាល ពោលគឺក្រោយពីទទួលបានឥទ្ធិពលនៃការដាក់អាណានិគមនិយមបារាំង និងបន្ទាប់ពីទទួលបានឯករាជ្យរហូតមកដល់បច្ចុប្បន្ន។

ដើម្បីធានាឲ្យបានសមភាពការងារ និងសំណាងផ្សេងៗដែលកើតមានលើកម្មករនិយោជិត នៅឆ្នាំ១៩៥៥ គេបានង្កើតឲ្យមានរបបសន្តិសុខសង្គមមួយសម្រាប់ធានាកម្មករនិយោជិត ប៉ុន្តែគួរឲ្យសោកស្តាយរបបសន្តិសុខសង្គមនេះ ត្រូវបានបំផ្លាញចោលទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍ ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ដែលមានរយៈពេល ០៣ឆ្នាំ ០៨ខែ និង២០ថ្ងៃ។ កំឡុងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ ប្រជាពលរដ្ឋទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ហើយនាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើងបន្ទាប់ពីការបោះឆ្នោតឆ្នាំ ១៩៩៣។ នាយកដ្ឋាននេះមានភារកិច្ចទទួលខុសត្រូវអនុវត្តកិច្ចការពារសន្តិសុខសង្គមដល់ប្រជាពលរដ្ឋ ដែលបំពេញការងារនៅក្នុងវិស័យឯកជន។ ដើម្បីឆ្លើយតបនឹងការកើនឡើង និងតម្រូវការរបស់កម្មករនិយោជិត ទើបរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ តាមរយៈច្បាប់នេះទើបឈានដល់ការបង្កើតគ្រឹះស្ថានសាធារណៈមួយនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ដោយអនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម។

បេឡាជាតិរបបសន្តិសុខសង្គមបានលេចចេញជារូបរាង ព្រមទាំងមានវត្តមានជាផ្លូវការនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។ បេឡាជាតិរបបសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមួយមានបេសកកម្មបម្រើសេវាសាធារណៈ ដែលមានលក្ខណៈសង្គមដល់សមាជិករបស់ខ្លួន និងស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គ្រឹះស្ថាននេះ បានកំពុងតែត្រៀមខ្លួនតាមរយៈការរៀបចំ ពង្រីក ពង្រឹង និងអភិវឌ្ឍសមត្ថភាពបន្ថែម ដោយមានចក្ខុវិស័យ និងបេសកកម្មច្បាស់លាស់ ក្នុងការអនុវត្តផ្នែកសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឲ្យទទួលបានសេវាសន្តិសុខសង្គមនៅពេលពួកគាត់ជួបប្រទះយថាភាពផ្សេងៗ ដូចជាជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗដូចជាជម្ងឺ និងមាតុភាពជាដើម។ បេឡាជាតិរបបសន្តិសុខសង្គមមិនត្រឹមតែជួយសម្រួល និងផ្តល់ភាពងាយស្រួលដល់កម្មករនិយោជិតប៉ុណ្ណោះទេ ព្រមទាំងជួយសម្រាលកាតព្វកិច្ចមួយចំនួនរបស់ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលពីមុនមកធ្លាប់តែជាអ្នកទទួលខុសត្រូវទាំងស្រុងក្នុងការផ្តល់ការព្យាបាល ថែទាំ ការគិតប្រាក់ឈ្នួលផ្សេងៗ ដល់កម្មករនិយោជិតដែលធានារ៉ាប់រងហានិភ័យការងារ និងផ្នែកថែទាំសុខភាពនៅប្រទេសកម្ពុជា។

ក្នុងស្ថានភាពដែលប្រទេសកម្ពុជាកំពុងតែរីកចម្រើន ការធានាលើផ្នែកសន្តិសុខសង្គមពិតសំខាន់ខ្លាំងណាស់ ដោយវាបានផ្តល់ការគាំពារចំពោះកម្មករនិយោជិតដែលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថានដោយផ្អែកទៅលើទស្សនទាននៃការចែករំលែក និងសាមគ្គីធម៌ គ្មានសមាជិកសង្គមណាម្នាក់ធ្លាក់ក្នុងហានិភ័យ និងក្រីក្រដោយងើបមិនរួចឡើយ។ ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម ដោយការធានាឲ្យបានសន្តិសុខប្រាក់ចំណូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម បេឡាជាតិរបបសន្តិសុខសង្គមបានអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររួមមាន ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនដែលគ្រោងនឹងអនុវត្តនាពេលឆាប់ៗខាងមុខនេះ។ ថ្វីត្បិតតែបេឡាជាតិរបបសន្តិសុខសង្គមបានបង្កើតឡើងក៏ពិតមែន ប៉ុន្តែមាននិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានមួយចំនួន មានការអល់អែកក្នុងការចុះបញ្ជិកា និងបង់ភាគទានឲ្យមកបេឡាជាតិរបបសន្តិសុខសង្គម ដោយពួកគេមួយចំនួនមិនទាន់មានការយល់ពីអត្ថប្រយោជន៍នៃគ្រឹះស្ថាននេះពោលគឺពុំទាន់មានទំនុកចិត្តនៅឡើយ។ ចំណែកកម្មករនិយោជិតវិញ ក៏មិនទាន់យល់ដឹងច្បាស់ពី

គ្រឹះស្ថាននេះដែរ ពោលគឺពុំដឹងពីសិទ្ធិរបស់ពួកគេ ពេលមានគ្រោះថ្នាក់ការងារ ការបាត់បង់សមត្ថភាពការងារ ការទទួលបានសេវាថែទាំ និងព្យាបាលវេជ្ជសាស្ត្រ និងមិនបានដឹងពីវិធីទទួលបានប្រយោជន៍ដ៏ច្រើនសន្ធឹកសន្ធាប់ពីបេឡាជាតិរបបសន្តិសុខសង្គម ដែលជាហេតុនាំឲ្យមានការខាតបង់យ៉ាងច្រើន។

ដើម្បីយល់កាន់តែច្បាស់អំពីប្រធានបទ "**បេឡាជាតិរបបសន្តិសុខសង្គមៈ ហានិភ័យការងារ និងសុខភាពកម្មករនិយោជិត**" យើងខ្ញុំសូមចូលខ្លួនមកបកស្រាយដោយធ្វើការបែងចែកជា ៣ជំពូក គឺ ទិដ្ឋភាពទូទៅ និងការគ្រប់គ្រងហិរញ្ញវត្ថុនៃបេឡាជាតិរបបសន្តិសុខសង្គម (ជំពូកទី១) របបធានារ៉ាប់រងហានិភ័យការងារនៃបេឡាជាតិរបបសន្តិសុខសង្គម (ជំពូកទី២) និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនៃបេឡាជាតិរបបសន្តិសុខសង្គម (ជំពូកទី៣)។

# ជំពូកទី១

# ទិដ្ឋភាពទូទៅ និងការគ្រប់គ្រងហិរញ្ញវត្ថុ

# នៃបេឡាជាតិរបបសន្តិសុខសង្គម

# ជំពូកទី១

# ទិដ្ឋភាពទូទៅ និងការគ្រប់គ្រងហិរញ្ញវត្ថុនៃបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម ជាគ្រឹះស្ថានមួយដែលបានបង្កើតឡើងដោយអនុលោមតាមអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម។ ដើម្បីយល់កាន់តែច្បាស់ពីគ្រឹះស្ថានសាធារណៈមួយនេះ យើងខ្ញុំនឹងបកស្រាយដោយផ្តោតសំខាន់ទៅលើះ

- ការរៀបចំ និងការប្រព្រឹត្តទៅនៃបេឡាជាតិរបបសន្តិសុខសង្គម
- ការគ្រប់គ្រងហិរញ្ញវត្ថុ

## ១.១. ការរៀបចំ និងការប្រព្រឹត្តទៅនៃបេឡាជាតិរបបសន្តិសុខសង្គម

### ១.១.១. លក្ខណៈទូទៅនៃបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម សរសេរជាអក្សរកាត់ **ប.ស.ស** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមួយដែលមានលក្ខណៈសង្គម និងមានបេសកកម្មបម្រើសេវាសាធារណៈ។ ស្ថាប័ននេះស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ[1]។ បេឡាជាតិរបបសន្តិសុខសង្គម ជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ[2]។ ប.ស.ស បានចាប់ផ្តើមដំណើរការជាផ្លូវការនៅចុងឆ្នាំ២០០៨ ចំណែក ឯការអនុវត្តគឺបែងចែកចេញជាជំហានៗ។

### ១.១.២. គោលបំណង និងតួនាទីរបស់បេឡាជាតិរបបសន្តិសុខសង្គម

#### ១.១.២.១. គោលបំណងបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានបង្កើតឡើងដោយមានគោលបំណងធ្វើយ៉ាងណាឲ្យទំនាក់ទំនងវិជ្ជាជីវៈ[3]រវាងនិយោជក និងកម្មករនិយោជិតមានភាពប្រសើរឡើង ពោលគឺជួយសម្រួលការលំបាករបស់កម្មករនិយោជិតនៅពេលដែលមាន ជរាភាព ទុព្វលភាព[4] មរណភាព ជម្ងឺ មាតុភាព ហានិភ័យការងារជាដើម។

---

[1]មាត្រា១ នៃអនុក្រឹត្យលខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[2]មាត្រា១ នៃអនុក្រឹត្យលខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[3]មានន័យថា មុខតំណែង មុខការ ឬរបបសម្រាប់ចិញ្ចឹមជីវិត(ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)

[4]មានន័យថា ភាពទ្រុឌទ្រោមខាងរាងកាយ ឬស្មារតីដែលមិនបណ្តាលមកពីគ្រោះថ្នាក់ការងារ និងមិនអាចបំពេញការងារបានមុនពេលសាមីជនអាយុ៥៥ឆ្នាំ (សៀវភៅនីតិការងារ និងនីតិនិរភ័យសង្គម សាស្ត្រាចារ្យ ហេង លីណា)

លើសពីនេះទៅទៀត បេឡាជាតិរបបសន្តិសុខសង្គមក៏បាន ជួយសម្រាលបន្ទុកនិយោជក នៅពេលដែលកម្មករនិយោជិតរបស់ខ្លួន មានគ្រោះថ្នាក់ការងារ ឬប្រឈមបញ្ហាផ្សេងៗដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់បេឡាជាតិរបបសន្តិសុខសង្គម[5]។

**១.១.២.២. ភារកិច្ចបេឡាជាតិរបបសន្តិសុខសង្គម**

- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ។
- ធានាផ្តល់ឲ្យបានសមស្របតាវកាលិកទាំងឡាយដល់សមាជិករបស់ខ្លួន ក្នុងគោលបំណងជួយសម្រាលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬជួបប្រទះយថាភាពផ្សេងៗទៀតដូចជា ជម្ងឺ និងការសម្រាកមាតុភាពជាដើម។
- ប្រមូលភាគទានពីសមាជិកបេឡាជាតិរបបសន្តិសុខសង្គម និងនិយោជក។
- សម្របសម្រួល និងធ្វើការរៀបចំឲ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិក[6]។
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ ជម្ងឺវិជ្ជាជីវៈ ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ អនាម័យការងារ សិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម[7]។

**១.១.៣. រដ្ឋបាលនៃបេឡាជាតិរបបសន្តិសុខសង្គម**

**១.១.៣.១. ក្រុមប្រឹក្សាភិបាល**

ប.ស.ស ត្រូវបានដឹកនាំដោយ ក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចក្នុងការគ្រប់គ្រងគ្រឹះស្ថាននេះ[8]។ ក្រុមប្រឹក្សាភិបាលមានសមាសភាព ៩រូបគឺ ៖

- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក

[5]មាត្រា១ នៃច្បាប់ស្តីពីសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ ចុះថ្ងៃទី ២៥/០២/២០០២

[6]មាត្រា៣ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[7]មាត្រា៣ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[8]មាត្រា៤ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប សមាជិក
- តំណាងក្រសួងសុខាភិបាល ១រូប សមាជិក
- តំណាងនិយោជក ២រូប សមាជិក
- តំណាងកម្មករនិយោជិតសមាជិកនៃ ប.ស.ស ២រូប សមាជិក
- នាយកនៃ ប.ស.ស សមាជិកស្វ័យប្រវត្តិ

ក្រុមប្រឹក្សាភិបាល ប.ស.ស មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តិទៅនៃ ប.ស.ស[9]។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ប.ស.ស ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្ម ព្រមទាំងធ្លាប់បម្រើការងារយ៉ាងតិច៥ឆ្នាំ ក្នុងចំណោមតស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ មានសមត្ថភាពក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលផ្តន្ទាទោសពីបទមជ្ឈឹម ឬឧក្រិដ្ឋ។ ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ប.ស.ស ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ៣ឆ្នាំ ដែលរៀបចំឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើររបស់ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈ ដែលសមាជិកនោះតំណាងឲ្យ[10]។

### ១.១.៣.២. អង្គការប្រតិបត្តិនៃបេឡាជាតិរបបសន្តិសុខសង្គម

#### ក. នាយក ប.ស.ស

នាយកនៃ ប.ស.ស ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយក ប.ស.ស មានភារកិច្ចចាត់ចែង និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ ប.ស.ស[11]។ អំណាចចាំបាច់ត្រូវតែប្រគល់ជូននាយក ប.ស.ស ដើម្បីឲ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ ពោលគឺជាតំណាងរបស់ ប.ស.ស ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវបានប្រគល់ឲ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ ប.ស.ស និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស[12]។ នាយក ប.ស.ស មានសិទ្ធិផ្ទេរអំណាចខ្លះ ឬទាំងអស់ ព្រមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬកំណត់ដោយក្រុមប្រឹក្សាភិបាល។

---

[9]មាត្រា៥ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[10]មាត្រា៦ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[11]មាត្រា១១ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[12]មាត្រា១២ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

**ខ. គណនេយ្យករ ប.ស.ស**

គណនេយ្យករ ប.ស.ស ត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គណនេយ្យករនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់របស់នាយក ប.ស.ស។

**គ. សមត្ថកិច្ចត្រួតពិនិត្យ**

ការត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃ ច្បាប់របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ នៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើដោយអធិការ ឬអភិបាលរបបសន្តិសុខសង្គម និងក្នុងករណីចាំបាច់ត្រូវសហការជាមួយអធិការការងារ ឬអភិបាលការងារ និងអង្គភាពពាក់ព័ន្ធដទៃទៀត។

ការតែងតាំង ការកំណត់តួនាទីភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើររបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស[13]។

**ឃ. បុគ្គលិកអចិន្ត្រៃយ៍របស់ប.ស.ស**

បុគ្គលិកអចិន្ត្រៃយ៍របស់ ប.ស.ស រួមមានមន្ត្រីរាជការស៊ីវិលក្នុងក្របខណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងនានា ឬមន្ត្រីដែលជ្រើសរើសតាមសំណើររបស់នាយក ប.ស.ស។ មន្ត្រីទាំងនេះត្រូវបានទទួលប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។ បុគ្គលិក ប.ស.ស ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាល ជាអ្នកកំណត់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

**ង. បុគ្គលិកជាប់កិច្ចសន្យា និងកម្មកររបស់ ប.ស.ស**

ប.ស.ស អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងកម្មករបាន។ បុគ្គលិកទាំងនេះត្រូវស្ថិតក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់ ប.ស.ស និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលតាមច្បាប់ស្តីពីការងារ[14]។

### ១.១.៤. របបធានារ៉ាប់រងក្នុងបេឡាជាតិរបបសន្តិសុខសង្គម

អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ដែលបានអនុម័តនៅ ឆ្នាំ២០០៧ គឺដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ បេឡាជាតិរបបសន្តិសុខសង្គម បានបង្កើតឡើងស្រប

[13] មាត្រា១៤ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[14] មាត្រា១៥ នៃអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

តាមច្បាប់សន្តិសុខសង្គមជាតិ និងបទប្បញ្ញត្តិសន្តិសុខសង្គមដោយអនុលោមតាមអនុក្រឹត្យ។ បេឡាជាតិរបបសន្តិសុខសង្គម បានចាប់ផ្ដើមដំណើរការឆ្នាំ ២០០៨ ដោយសារតែ ប.ស.ស គឺជាគ្រឹះស្ថានសាធារណៈថ្មីមួយដែលទើបនឹងបង្កើត ជាហេតុនាំឱ្យមានការរៀបចំយុទ្ធសាស្ត្រក្នុងការអនុវត្តជាដំណាក់កាល។ ផ្អែកតាមគោលនយោបាយសន្តិសុខសង្គម ដែលមានចែងក្នុងច្បាប់ជាធរមាន របបធានារ៉ាប់រងរបស់បេឡាជាតិរបបសន្តិសុខសង្គមរួមមាន ការធានាផ្តល់តាវកាលិកផ្នែកប្រាក់សោធន ការផ្តល់តាវកាលិកហានិភ័យការងារ និងផ្នែកដទៃទៀតជាបន្តបន្ទាប់តាមស្ថានភាពជាក់ស្តែងនៃសង្គម និងសេដ្ឋកិច្ចជាតិ[15]។

ដំណាក់កាលអនុវត្តនៃបេឡាជាតិរបបសន្តិសុខសង្គមមាន៣ផ្នែក ជាអាទិ៍របបធានារ៉ាប់រងហានិភ័យការងារ របបធានារ៉ាប់រងសុខភាព និងរបបប្រាក់សោធន។ ការចាប់ផ្តើមអនុវត្តជំហានដំបូងរបស់ ប.ស.ស គឺរបបធានារ៉ាប់រងហានិភ័យការងារក្នុងឆ្នាំ ២០០៨[16]។ បន្ទាប់ពីទទួលបានភាពជោគជ័យក្នុងដំណាក់កាលទីមួយ និងដើម្បីយកចិត្តទុកដាក់លើការថែទាំសុខភាព កម្មករនិយោជិត ប.ស.ស បានចាប់ផ្តើមបន្តការអនុវត្តដំណាក់កាលបន្ទាប់គឺ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត នៅថ្ងៃ០១ ខែឧសភា ឆ្នាំ២០១៦[17]។ ចំណែកឯផ្នែកប្រាក់សោធន បច្ចុប្បន្នកំពុងធ្វើការសិក្សា នឹងអាចចាប់ផ្តើមអនុវត្តនាពេលឆាប់ៗនេះ។

## ១.២. ការគ្រប់គ្រងហិរញ្ញវត្ថុ

### ១.២.១. កិច្ចការគណនេយ្យ

ប.ស.ស កាន់កាប់គណនេយ្យរបស់ខ្លួនស្របតាមគោលការណ៍គណនេយ្យសាធារណៈ និងវិធានគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កាលបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែល។ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣១ ខែមិនា នៃកាលបរិច្ឆេទបន្ទាប់[18]។

អាណាប័កដើមខ្សែរបស់គ្រឹះស្ថាន គឺជានាយក ប.ស.ស ដែលមានភារកិច្ច ពិនិត្យប្រាក់ និងទូទាត់ចំណូល ព្រមទាំងចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ។

---

[15]មាត្រា១ នៃច្បាប់ស្តីពីសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ ចុះថ្ងៃទី ២៥/០២/២០០២

[16]ប្រការ១ នៃប្រកាសលខ០២២/០៨ កប.ប្រក ចុះថ្ងៃទី១១/០២/២០០២ ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

[17]ប្រការ៥ នៃប្រកាសលខ០៩៣/១៦ កប.ប្រក ចុះថ្ងៃទី០៧/០៣/២០១៦ ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

[18]មាត្រា១៧ នៃអនុក្រឹត្យលខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ ប.ស.ស ក្រោមការទទួលខុសត្រូវផ្ទាល់ពីគណនេយ្យករ។ គណនេយ្យករនេះត្រូវធ្វើសច្ចាប្រណិធានមុននឹងចូលកាន់តំណែង។ គណនេយ្យករ មានភារកិច្ចប្រមូលចំណូល បើកប្រាក់ចំណាយ រក្សាទុក និងចាត់ចែងប្រើប្រាស់មូលនិធិ ប.ស.ស ព្រមទាំងរក្សាទុកលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ។

### ១.២.២. ប្រភពធនធាន

ជាទូទៅស្ថាប័ន ឬអង្គភាពមួយអាចដំណើរការបាន គឺអាស្រ័យលើប្រភពធនធានដែលទទួលបាន។ ចំណែក ប.ស.ស វិញក៏ដូចគ្នាដែរ ប្រភពធនធានគឺជាកត្តាមួយដ៏សំខាន់ដែលជម្រុញឱ្យ ប.ស.ស អាចដំណើរការបាន។ ប្រភពធនធានរបស់ ប.ស.ស គឺ[19]៖

- ការឧបត្ថម្ភពីរដ្ឋដើម្បីបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ដែលជាប្រភពធនធានដំបូងដែល ប.ស.ស ទទួលបាន។
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈ ដែលមានចែងនៅក្នុងថវិការដ្ឋ ដូចជាឧបត្ថម្ភធនធានសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន។
- ភាគទានរបស់សមាជិក ប.ស.ស និងនិយោជិត ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។
- ប្រាក់ពិន័យពីការយឺតយូរក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនេះ។
- ផលចំណេញដែលបានមកពីការវិនិយោគ
- អំណោយ និងអច្ច័យទានផ្សេងៗ
- និងប្រភពដទៃទៀតដែល ប.ស.ស អាចទទួលបានដោយស្របច្បាប់។

### ១.២.៣. ការចំណាយ

ការចំណាយគឺជាបន្ទុករបស់ ប.ស.ស ដែលរួមមាន៖

- ការចំណាយសម្រាប់តារកាលិកលើផ្នែកនីមួយៗ[20] មានដូចជា គ្រោះថ្នាក់ការងារ គ្រោះថ្នាក់នៅពេលធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីទីកន្លែងធ្វើការ ឆ្ពោះទៅលំនៅស្ថាន និងជម្ងឺវិជ្ជាជីវៈ។ ការចំណាយលើតារកាលិកនៃហានិភ័យការងារដែលរួមមាន តារកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាបណ្តោះ

[19]មាត្រា២០ នៃអនុក្រឹត្យលខ១៦អនក្រ.បក ចុះថ្ងៃទី០២/៣/២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[20]ប្រការ១ នៃប្រកាសលេ2ខ១០៩កប/ប្រក ចុះថ្ងៃទី១៦/៦/២០០៨ ស្តីពីតារកាលិកហានិភ័យការងារ

អាសន្ននៅពេលកម្មករនិយោជិតរងគ្រោះថ្នាក់, ផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍, ប្រាក់វិភាជន៍ជាសោហ៊ុយសម្រាប់បូជាសព, ផ្តល់តាវកាលិកឧត្តរជីវី និងប្រាក់បន្ថែមសម្រាប់អ្នកដែលនៅថែរក្សាជនរងគ្រោះ។

- ការចំណាយសម្រាប់ការងាររដ្ឋបាល ប.ស.ស។
- ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច។
- ការចំណាយលើការវិនិយោគដើម្បីជាប្រយោជន៍របស់ ប.ស.ស ។

លើសពីនេះទៀត ប.ស.ស ក៏មានប្រាក់ត្រៀមបម្រុងអប្បបរមាសម្រាប់ផ្នែកហានិភ័យការងារ ដែលប្រាក់នេះត្រូវស្មើនឹងចំនួនទឹកប្រាក់ចំណាយសម្រាប់ធនលាភដែលបានឧបត្ថម្ភកន្លងទៅ និង១/២នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃក្រៅពីលាភធនក្នុងអំឡុងពេល ២ឆ្នាំចុងក្រោយ។ ម្យ៉ាងវិញទៀត ចំពោះមូលនិធិបង្វិលមួយត្រូវបានបង្កើតឡើងឲ្យមានសម្រាប់ការចំណាយនៃផ្នែកទាំងឡាយរបស់របបសន្តិសុខសង្គម។ មូលនិធិនេះមិនត្រូវតិចជាង ២ដងនៃការចំណាយជាមធ្យមប្រចាំខែរបស់ ប.ស.ស នៅក្នុងអំឡុងឆ្នាំចុងក្រោយឡើយ។

# ជំពូកទី២

# របបធានារ៉ាប់រងហានិភ័យការងារ

# នៃបេឡាជាតិរបបសន្តិសុខសង្គម

# ជំពូកទី២

# របបធានារ៉ាប់រងហានិភ័យការងារនៃបេឡាជាតិរបបសន្តិសុខសង្គម

ជាទូទៅកម្មករនិយោជិតដែលបម្រើការងារនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយរមែងជួបប្រទះបញ្ហាផ្សេងៗទាក់ទងនឹងហានិភ័យការងារ ដែលនាំឲ្យពួកគេជួបផលវិបាក ពោលគឺបាត់បង់សមត្ថភាពការងារដែលជាហេតុបណ្តាលឲ្យពួកគេមិនអាចបំពេញការងារបាន។ លើសពីនេះទៀត វាអាចនាំឲ្យមានជម្លោះ កើតឡើងរវាងកម្មករនិយោជិត និងនិយោជកទាក់ទងការទទួលខុសត្រូវ និងការទាមទារសំណង។ ដើម្បីជួយសម្រួល និងដោះស្រាយបញ្ហាទាំងនេះ បេឡាជាតិរបបសន្តិសុខសង្គមបានបង្កើតឲ្យមានរបបធានារ៉ាប់រងហានិភ័យការងារជូនកម្មករនិយោជិត។

របបធានារ៉ាប់រងហានិភ័យការងារ គឺជាផ្នែកមួយរបស់បេឡាជាតិរបបសន្តិសុខសង្គមដែលបានដាក់ឲ្យអនុវត្តចាប់ពីឆ្នាំ២០០៨ យោងតាមប្រកាសលេខ០២២/០៨ កប-ប្រកចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ។ ដំណាក់កាលចាប់ផ្តើមដំបូង ផ្នែកធានារ៉ាប់រងហានិភ័យការងារ ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ០៨នាក់ឡើងទៅ។ ចំពោះសហគ្រាសគ្រឹះស្ថានផ្សេងពីនេះ ត្រូវបន្តអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររហូតដល់មានការកំណត់ថ្មី[21] ។ ដើម្បីយល់ច្បាស់ពីរបបធានារ៉ាប់រងហានិភ័យការងារនៃបេឡាជាតិរបបសន្តិសុខសង្គម ជំពូកទី២ នៃសារណានេះយើងខ្ញុំនឹងធ្វើការបកស្រាយជា៣ផ្នែក

- ការចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម
- ការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានហានិភ័យការងារ
- តាវកាលិកហានិភ័យការងារ

## ២.១. ការចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម

សហគ្រាស គ្រឹះស្ថានទាំងអស់ ដើម្បីទទួលបានការទទួលខុសត្រូវរបបធានារ៉ាប់រងហានិភ័យការងារលុះត្រាតែម្ចាស់សហគ្រាស គ្រឹះស្ថាននោះបានចុះបញ្ជិការបបធានារ៉ាប់រងហានិភ័យការងារក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

[21]ប្រការ២ នៃប្រកាសលេខ០២២/០៨ កប-ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

និយោជក ត្រូវចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតរបស់ខ្លួនដោយអនុវត្ត តាមប្រកាសលេខ០២១/០៨ កប-ប្រក ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង បេឡាជាតិរបបសន្តិសុខសង្គម ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

### ២.១.១. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

#### ២.១.១.១. លក្ខខណ្ឌទូទៅ

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ ត្រូវមាន កាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួនក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

ចំពោះរយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន បានកំណត់ដូចខាងក្រោម៖

- ចំពោះសហគ្រាស គ្រឹះស្ថានដែលកំពុងដំណើរការត្រូវមកចុះបញ្ជិកាក្នុងរយៈពេល យ៉ាងយូរ៤៥ (សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីប្រកាសលេខ២១ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម ចូលជាធរមាន។
- ចំពោះសហគ្រាស គ្រឹះស្ថានដែលបើកដំណើរការក្រោយកាលបរិច្ឆេទចូលជាធរ មាននៃប្រកាសលេខ២១ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គមឆ្នាំ២០០៨ ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាង យូរ៤៥ (សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះ ស្ថានជាស្ថាពរ[22]។

ទោះបីជាមានការកំណត់រយៈពេលហើយក៏ដោយ ប៉ុន្តែនៅក្នុងការអនុវត្តដំណាក់ កាលដំបូងនៃរបបធានារ៉ាប់រងហានិភ័យការងារនេះ ប.ស.ស នៅតែផ្តល់ឱកាសដល់សហគ្រាស គ្រឹះស្ថានដែលមិនទាន់បានចុះបញ្ជិកានៅ ប.ស.ស ដោយ ប.ស.ស បានធ្វើការអញ្ជើញម្ចាស់ ឬ តំណាង សហគ្រាស គ្រឹះស្ថានតាមលិខិតអញ្ជើញផ្លូវការ និងចុះធ្វើអធិការកិច្ច ទាក់ទងពីការកំណត់ រយៈពេលនៅក្នុងការចុះបញ្ជិកា ព្រមទាំងកាលបរិច្ឆេទចាប់ផ្តើមបង់ភាគទាន។

ជាមួយគ្នានេះការអញ្ជើញនិយោជកមកចុះឈ្មោះ នៅពេលដែលបេឡាជាតិរបប សន្តិសុខសង្គម ដាក់កំណត់រយៈពេលរួចមក និយោជកត្រូវមកធ្វើការចុះបញ្ជិកា ហើយនិយោជក

[22]ប្រការ១ នៃប្រកាសលេខ០២១/០៨ កប-ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបប សន្តិសុខសង្គម ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨

នឹងជាប់កាតព្វកិច្ចចុះបញ្ជិកា និងជាប់ភាគទានចាប់តាំងពីកាលបរិច្ឆេទដែល ប.ស.ស បានដាក់កំហិត[23]។

ក្នុងករណីដែលតំណាង ឬម្ចាស់សហគ្រាស គ្រឹះស្ថាន នៅតែមិនព្រមមកចុះបញ្ជិកានៅក្នុងប.ស.ស តាមកាលបរិច្ឆេទរបស់ ប.ស.ស ទេនោះប.ស.ស នឹងចាត់វិធានការតាមនីតិវិធីច្បាប់ ដោយផាកពិន័យទៅតាមកំរិតបទល្មើសដែលច្បាប់បានចែង[24]។ ករណីដែលនៅតែចចេសមិនព្រមបង់ប្រាក់ផាកពិន័យទេនោះ ប.ស.ស នឹងរៀបចំសំណុំឯកសារដើម្បីប្តឹងទៅតុលាការ និងធ្វើការដោះស្រាយតាមនីតិវិធីច្បាប់។

### ២.១.១.២. បែបបទនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

និយោជក ឬម្ចាស់សហគ្រាសត្រូវបំពេញបែបបទបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួនរួចបញ្ជូនមក ប.ស.ស ដើម្បីធ្វើការចុះបញ្ជិកា តាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ "១.០១"[25]។ ដើម្បីចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាននៅប.ស.ស និយោជកត្រូវគោរពបែបបទដូចខាងក្រោម៖

- បំពេញឈ្មោះសហគ្រាស គ្រឹះស្ថានជាអក្សរខ្មែរ និងជាអក្សរឡាតាំង
- បំពេញអាស័យដ្ឋានរបស់ទីស្នាក់ការកណ្តាល អាស័យដ្ឋានកន្លែងធ្វើការងារ ឬធ្វើអាជីវកម្ម
- បំពេញឈ្មោះ លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន អាស័យដ្ឋានអចិន្ត្រៃយ៍របស់និយោជក ឬអ្នកតំណាង
- មានប័ណ្ណចុះបញ្ជិកាពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬឯកសារគតិយុត្តនៃក្រសួងពាក់ព័ន្ធដទៃទៀតភ្ជាប់ទៅជាមួយ
- បំពេញថ្ងៃ ខែចាប់ផ្តើមជំនួញ ត្រូវគិតចាប់ពីថ្ងៃដែលបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាននៅក្នុងក្រសួងពាណិជ្ជកម្ម ឬនៅក្រោមក្រសួងដែលពាក់ពន្ធ័ដទៃទៀត។

---

[23]ប្រការ១ នៃប្រកាសលេខ១០៨កប/ចុះថ្ងៃទី១៦/០៦/២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

[24] មាត្រា៣៦ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២

[25]ប្រការ៣ និងឧបសម្ព័ន្ធ១នៃ ប្រកាសលេខ០២១ កប/ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថានក្នុងបេឡាជាតិរបបសន្តិសុខសង្គម

#### ២.១.១.៣. អត្តសញ្ញាណកម្មសហគ្រាស គ្រឹះស្ថាន

ប.ស.ស ត្រូវផ្តល់លេខអត្តសញ្ញាណមួយសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ បន្ទាប់ពីទទួលបានទម្រង់ បញ្ជិកាសហគ្រាស គ្រឹះស្ថាន។ ប.ស.ស នឹងផ្តល់វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន បន្ទាប់ពីចុះបញ្ជិការួចទៅឲ្យនិយោជក ដែលក្នុងនោះមានលេខអត្តសញ្ញាណសហគ្រាសគ្រឹះស្ថាន និងកាលបរិច្ឆេទចុះបញ្ជិកា។

ចំណែកនិយោជក ត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាននៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន[26]។

### ២.១.២. ការចុះបញ្ជិកាកម្មករនិយោជិត

#### ២.១.២.១. ទម្រង់បញ្ជិកាកម្មករនិយោជិត

ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើឡើងតាមទម្រង់ "បញ្ជិកាកម្មករនិយោជិត" ឬទម្រង់"១.០២"[27]។ ទម្រង់បញ្ជិកាកម្មករនិយោជិត ដែលត្រូវផ្ញើជូនបេឡាជាតិរបបសន្តិសុខសង្គម អាចធ្វើតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានលិខិតបញ្ជាក់ដែលចុះហត្ថលេខានាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។ ដើម្បីចុះបញ្ជិកាកម្មករនិយោជិត នៅប.ស.ស ត្រូវគោរពបែបបទដូចខាងក្រោម៖

- ត្រូវបំពេញគោត្តនាម និងនាមរបស់កម្មករនិយោជិត ដូចគ្នានិង គោត្តនាម និងនាមដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណ ឬសំបុត្របញ្ជាក់កំណើត ក្នុងករណីដែលឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណ និងឈ្មោះក្នុងសំបុត្របញ្ជាក់កំណើតខុសគ្នា ត្រូវយកឈ្មោះដូចសំបុត្របញ្ជាក់កំណើត។
- លេខអត្តសញ្ញាណកម្មករនិយោជិត ដែលចេញដោយ ប.ស.ស។

ករណីមានការផ្លាស់ប្តូរពត៌មានរបស់កម្មករនិយោជិត និយោជកត្រូវបញ្ជាក់អំពីការផ្លាស់ប្តូរឲ្យបានច្បាស់លាស់ ដោយភ្ជាប់ជាមួយលិខិតស្នើសុំប្តូរមក ប.ស.ស ដើម្បីធ្វើការកែតម្រូវ។

#### ២.១.២.២. អត្តសញ្ញាណកម្មនៃកម្មករនិយោជិត

ដូចបានបកស្រាយខាងលើ និយោជក មានកាតព្វកិច្ចចុះបញ្ជិកាកម្មករនិយោជិត ឲ្យកម្មករនិយោជិតរបស់ខ្លួន នៅបេឡាជាតិរបបសន្តិសុខសង្គម។ ដូចនេះបន្ទាប់ពីទទួលបានទម្រង់

[26]ប្រការ៤.២ នៃប្រកាសលេខ០២១/០៨ កប-ប្រកស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨

[27]ប្រការ៣.២ និងឧបសម្ព័ន្ធ ២ នៃប្រកាសលេខ០២១ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថានក្នុងបេឡាជាតិរបបសន្តិសុខសង្គមចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨

បញ្ជិកាកម្មករនិយោជិត បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់លេខអត្តសញ្ញាណ និងចេញប័ណ្ណធានារ៉ាប់រងហានិភ័យការងារ ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ ប័ណ្ណធានារ៉ាប់រងហានិភ័យការងារ ត្រូវប្រគល់ជូនទៅកម្មករនិយោជិត តាមរយៈនិយោជក។ ក្នុងករណីដែលប័ណ្ណធានារ៉ាប់រងហានិភ័យការងារ ខូច ឬបាត់បង់ សាមីជនដែលជាម្ចាស់ប័ណ្ណត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជិក និងត្រូវស្នើសុំទុតិយតា ក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងខាងលើ។ ការផ្តល់ប័ណ្ណទុតិយតា តម្រូវឲ្យសាមីជនបង់ប្រាក់ចំនួន ២០០០ (ពីរពាន់) រៀលជូនទៅបេឡាជាតិរបបសន្តិសុខសង្គម តាមរយៈនិយោជក ឬអ្នកតំណាង[28]។

### ២.១.២.៣. របាយការណ៍ចំនួនកម្មករនិយោជិត

រៀងរាល់ខែ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិត ទៅបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍។ របាយការណ៍ចំនួនកម្មករនិយោជិត ដែលត្រូវផ្តល់ជូនបេឡាជាតិរបបសន្តិសុខសង្គម អាចធ្វើតាមទម្រង់ក្រដាស ឬទម្រង់អេឡិចត្រូនិច ដោយមានភ្ជាប់លិខិតបញ្ជូន និងចុះហត្ថលេខាដោយនិយោជិក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន[29]។ គោលបំណងនៃការធ្វើរបាយការណ៍គឺដើម្បីចុះឈ្មោះកម្មករនិយោជិតថ្មី និងធ្វើការលុបឈ្មោះចំពោះកម្មករនិយោជិតដែលបានឈប់ពីការងារ។ ប៉ុន្តែការលុបឈ្មោះនេះ គឺធ្វើនៅខែបន្ទាប់ចំពោះខែដែលបានឈប់ ឬបញ្ឈប់កម្មករនិយោជិតទោះធ្វើការបានមួយថ្ងៃ ក៏ត្រូវធ្វើរបាយការណ៍ជូន ប.ស.សដែរ។

## ២.២. ការកំណត់អត្រាភាគទាន និងបែបបទបង់ភាគទានរបបហានិភ័យការងារ

### ២.២.១. កាតព្វកិច្ចបង់ភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលស្ថិតនៅក្រោមច្បាប់ស្តីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារ។ ភាគទានក្នុងផ្នែកហានិភ័យការងារ គឺបានមកពីប្រភពមួយដ៏សំខាន់ពោលគឺ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ។

---

[28]ប្រការ៤ថ្មី នៃប្រកាសស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ ប្រកាសលេខ០២១កប/ប្រកចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

[29]ប្រការ៥ថ្មី នៃប្រកាសស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ ប្រកាសលេខ០២១កប/ប្រកចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន មានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារជូន ប.ស.សរៀងរាល់ខែ ដោយនិយោជកមិនអាចកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិត ដើម្បីបង់ភាគទាននេះជាដាច់ខាត[30]។ ចំណែកការគណនាភាគទាននេះ ត្រូវគិតតាមអត្រាប្រាក់ឈ្នួលមធ្យមប្រចាំខែរបស់កម្មករនិយោជិត។

### ២.២.២. អត្រាភាគទានហានិភ័យការងារ

និយោជកត្រូវបង់ភាគទានជូន ប.ស.ស ដោយផ្អែកលើអត្រា ០.៨% នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលសរុបប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗ[31]។ ក្នុងករណីសហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេស អត្រានៃប្រាក់ឈ្នួលមធ្យមខាងលើត្រូវទូទាត់តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។ អត្រាភាគទានត្រូវបានកំណត់ជាថ្មីដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមស្ថានភាពជាក់ស្តែងនៃបម្រែបម្រួលវិស័យឧស្សាហកម្មនៅកម្ពុជា និងតាមចំណាត់ថ្នាក់ឧស្សាហកម្ម។

ការបង់ភាគទានអត្រា០.៨% ផ្អែកលើតារាងដូចខាងក្រោម[32] ដោយចំនួនប្រាក់ឈ្នួលរបស់កម្មករនិយោជិត ជាអប្បបមា២០០,០០០រៀលចុះ និងចំនួនអតិបរិមាត្រឹម១.០០០.០០១ រៀលឡើង

| ប្រាក់ឈ្នួលប្រចាំខែ (រៀល) | ប្រាក់ឈ្នួលមធ្យមប្រចាំខែ (រៀល) | ភាគទានប្រចាំខែសម្រាប់កម្មករនិយោជិតម្នាក់ (រៀល) |
|---|---|---|
| ២០០.០០០ចុះ | ២០០.០០០ | ១.៦០០ |
| ២០០.០០១-២៥០.០០០ | ២២៥.០០០ | ១.៨០០ |
| ២៥០.០០១-៣០០.០០០ | ២៧៥.០០០ | ២.២០០ |
| ៣០០.០០១-៣៥០.០០០ | ៣២៥.០០០ | ២.៦០០ |
| ៣៥០.០០១-៤០០.០០០ | ៣៧៥.០០០ | ៣.០០០ |
| ៤០០.០០១-៤៥០.០០០ | ៤២៥.០០០ | ៣.៤០០ |

[30]ប្រការ១ នៃប្រកាសលេខ១០៨កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

[31]ប្រការ២ និងឧបសម្ព័ន្ធ១ នៃប្រកាសលេខ១០៨កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការ បង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

[32]ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ១០៨ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានហានិភ័យការងារ

| | | |
|---|---|---|
| ៤៥០.០០១-៥០០.០០០ | ៤៧៥.០០០ | ៣.៨០០ |
| ៥០០.០០១-៥៥០.០០០ | ៥២៥.០០០ | ៤.២០០ |
| ៥៥០.០០១-៦០០.០០០ | ៥៧៥.០០០ | ៤.៦០០ |
| ៦០០.០០១-៦៥០.០០០ | ៦២៥.០០០ | ៥.០០០ |
| ៦៥០.០០១-៧០០.០០០ | ៦៧៥.០០០ | ៥.៤០០ |
| ៧០០.០០១-៧៥០.០០០ | ៧២៥.០០០ | ៥.៨០០ |
| ៧៥០.០០១-៨០០.០០០ | ៧៧៥.០០០ | ៦.២០០ |
| ៨០០.០០១-៨៥០.០០០ | ៨២៥.០០០ | ៦.៦០០ |
| ៨៥០.០០១-៩០០.០០០ | ៨៧៥.០០០ | ៧.០០០ |
| ៩០០.០០១-៩៥០.០០០ | ៩២៥.០០០ | ៧.៤០០ |
| ៩៥០.០០១-១.០០០.០០០ | ៩៧៥.០០០ | ៧.៨០០ |
| ១.០០០.០០០ឡើង | ១.០០០.០០០ | ៨.០០០ |

- **រូបមន្តក្នុងការគណនាប្រាក់បង់ភាគទានហានិភ័យការងារ**

**ដើម្បីគណនាប្រាក់នៃការបង់ភាគទានហានិភ័យការងារ = ប្រាក់ឈ្នួលមធ្យមរបស់កម្មករនិយោជិត x 0,៨ភាគរយ (0,00៨)**

**ឧទាហរណ៍**

១. កម្មករនិយោជិត មានប្រាក់ឈ្នួលប្រចាំខែតិចជាង ២០០.០០០រៀល នោះប្រាក់ឈ្នួលមធ្យមត្រូវកំណត់ស្មើនឹង ២០០.០០០រៀល ក្នុងខែនីមួយៗ យើងអាចទាញបាន ៖

២០០.០០០៛ x 0,00៨ = **១.៦០០៛ ជាប្រាក់ដែលជាប់ភាគទានប្រចាំខែ**

២.កម្មករនិយោជិតមានប្រាក់ឈ្នួលប្រចាំខែចន្លោះពី២០០.០០១រៀល ទៅ២៥០.០០០រៀល នោះប្រាក់ឈ្នួលមធ្យមត្រូវ កំណត់ស្មើនឹង ២២៥.០០០រៀល ក្នុងខែនីមួយៗ យើងអាចទាញបាន ៖

២២៥.០០០៛ x 0,00៨ = **១.៨០០៛ ជាប្រាក់ដែលជាប់ភាគទានប្រចាំខែ**

### ២.២.៣. កាលបរិច្ឆេទបង់ភាគទាន

កាលបរិច្ឆេទបង់ភាគទានដំបូង ត្រូវបានកំណត់ក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែល ប.ស.ស បានចេញវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន។ ការប្រគល់ វិញ្ញាបនបត្រត្រូវ

មានបញ្ជាក់កាលបរិច្ឆេទដែលសហគ្រាស គ្រឹះស្ថានបានទទួលពី ប.ស.ស។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានសម្រាប់ខែនីមួយៗយ៉ាងយូរបំផុតថ្ងៃទី១៥ នៃខែបន្ទាប់។ ចំពោះការខកខានមិនបានបង់ភាគទានតាមកាលបរិច្ឆេទបានកំណត់ និយោជកត្រូវបង់បន្ថែមការប្រាក់តាមចំនួនជាក់ស្តែង និងត្រូវពិន័យជាប្រាក់តាមអត្រាអប្បបរមានៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ[33]។

### ២.២.៤. បែបបទបង់ភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលមានកាតព្វកិច្ចបង់ភាគទានជូនបេឡាជាតិរបបសន្តិសុខសង្គមត្រូវគោរពតាមបែបបទនៃការបង់ភាគទាន។ និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថានត្រូវបង់ភាគទានដោយផ្ទាល់ចូលទៅក្នុងគណនីរបស់បេឡាជាតិរបបសន្តិសុខសង្គមដែលស្ថិតនៅធនាគារអេស៊ីលីដា ភីអិលស៊ី ឬតាមបណ្តាសាខានៃធនាគារនេះ[34]។ បន្ទាប់ពីថ្ងៃដែលបានបង់ហើយ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវផ្ញើបង្កាន់ដៃបង់ភាគទានដែលចេញដោយធនាគារមក ប.ស.ស ដែលបង្កាន់ដៃបង់ភាគទាននេះត្រូវមានចុះលេខអត្តសញ្ញាណសហគ្រាសគ្រឹះស្ថាន និងកាលបរិច្ឆេទនៃការបង់ភាគទាន។

ដូចនេះបន្ទាប់ពី ប.ស.ស ទទួលបានបង្កាន់ដៃបង់ភាគទានពីនិយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន ប.ស.ស ត្រូវចេញលិខិតបញ្ជាក់ពីការទទួលបានប្រាក់ភាគទានជូនទៅសហគ្រាសគ្រឹះស្ថានវិញ។ ក្នុងករណីពិនិត្យឃើញថា ភាគទានដែលបានបង់មិនគ្រប់ចំនួន ប.ស.ស ត្រូវកំណត់ឲ្យសហគ្រាស គ្រឹះស្ថានបង់បង្គ្រប់តាមចំនួនជាក់ស្តែងតាមទម្រង់បែបបទភាគទានបង្គ្រប់។

## ៣.៣. តាវការលិកហានិភ័យការងារ

ហានិភ័យ ឬគ្រោះថ្នាក់ គឺជាគ្រោះដែលយើងមិនអាចដឹង ឬប៉ាន់ស្មានមុនបានឡើយ។ ជាទូទៅកម្មករនិយោជិតតែងតែប្រឈមនឹងគ្រោះថ្នាក់ការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពក្នុងការបំពេញមុខងារ ដែលជាហេតុធ្វើឲ្យបាត់បង់ប្រាក់ចំណូលសម្រាប់ចិញ្ចឹមគ្រួសារ។ ប៉ុន្តែប្រសិនបើនិយោជកបានគោរពកាតព្វកិច្ច និងធ្វើតាមលក្ខខណ្ឌរបស់ ប.ស.ស នោះនៅពេលដែលកម្មករនិយោជិតខ្លួនជួបហានិភ័យការងារ ប.ស.ស នឹងទទួលរ៉ាប់រងផ្តល់តាវកាលិកឲ្យដោយគោរពតាមលក្ខខណ្ឌ និងច្បាប់ដែលមានចែង។

---

[33]ប្រការ៣ នៃប្រកាសលេខ១០៨កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

[34]ចំនុច២ ក្នុង១ នៃសេចក្តីជូនដំណឹងលេខ ១១២/ប ស ស/ស ជ ណ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨របស់បេឡាជាតិរបបសន្តិសុខសង្គម

ហានិភ័យការងារ គឺជាគ្រោះថ្នាក់ការងារដែលគ្រោះថ្នាក់ទាំងនោះរួមមាន៖ គ្រោះថ្នាក់ពេលបំពេញការងារ គ្រោះថ្នាក់នៅពេលធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការឆ្ពោះទៅលំនៅស្ថាន និងជម្ងឺវិជ្ជាជីវៈ។

### ៣.៣.១. និយមន័យ

#### ៣.៣.១.១. គ្រោះថ្នាក់ការងារ

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ក្នុងករណីគ្រោះថ្នាក់នោះធ្លាក់លើរូបកាយកម្មករនិយោជិតដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ ពោលគឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលបំពេញការងារឲ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី អត់ឈ្នួលក្តី កាន់មុខងារជាអ្វីនៅទីកន្លែងណាក៏ដោយ[35]។

#### ៣.៣.១.២. ពេលធ្វើដំណើរទៅកន្លែងការងារ

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឲ្យទៅ[36]។

#### ៣.៣.១.៣. ជម្ងឺវិជ្ជាជីវៈ

ជម្ងឺវិជ្ជាជីវៈជាជម្ងឺ ដែលកើតមានឡើងដោយសារលទ្ធផលនៃការងារ ឬសកម្មភាពការងារដែលកម្មករនិយោជិតកំពុងធ្វើ ឬបានធ្វើរួចមកហើយនៅក្នុងសហគ្រាសរបស់ខ្លួន ហើយអាចបង្កឲ្យកើតជម្ងឺនៅពេលក្រោយមកទៀត។

ទោះបីកម្មករនិយោជិតបានលាឈប់ពីការងារហើយ ប៉ុន្តែមានជម្ងឺដែលត្រូវបានគេប្រកាសថាជាហានិភ័យការងារ ក៏អាចបើកសិទ្ធិឲ្យកម្មករនិយោជិតនោះទទួលបានតាវកាលិកសម្រាប់ហានិភ័យការងារបានដែរ បើការប្រកាសនោះស្ថិតនៅក្នុងអំឡុងពេលដែលមានបញ្ជាក់ក្នុងបញ្ជីនៃជម្ងឺវិជ្ជាជីវៈដែលមានចែងក្នុងប្រកាសរួមរបស់ក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ រដ្ឋមន្ត្រីក្រសួង ដែលទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងរដ្ឋមន្ត្រី

[35] មាត្រា១២ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[36] មាត្រា១២ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

ក្រសួងសុខាភិបាលត្រូវចេញប្រកាសរួមស្តីពីការកំណត់បញ្ជីជម្ងឺវិជ្ជាជីវៈ ដោយភ្ជាប់មកជាមួយបញ្ជីនៃមុខរបរប្រើកម្លាំងកាយ មុខរបរដែលប៉ះពាល់ដោយជាតិពុល និងមុខរបរដែលត្រូវអនុវត្តនៅក្នុងលក្ខខណ្ឌ ឬតំបន់មានលក្ខណៈមិនប្រក្រតី ដែលនាំឲ្យអ្នកធ្វើការកើតជម្ងឺផ្សេងៗ បន្ទាប់ពីការផ្តល់យោបល់ពីក្រុមប្រឹក្សាបច្ចេកទេស[37]។

ជារួមដើម្បីកំណត់គ្រោះថ្នាក់មួយជាគ្រោះថ្នាក់ការងារ ឬក៏គ្រោះថ្នាក់ពីកន្លែងធ្វើការទៅលំនៅស្ថាន ឬពីលំនៅស្ថានទៅកន្លែងធ្វើការ ពេលខ្លះអាចមានការស្មុគស្មាញ នៅពេលខ្លះគ្រោះថ្នាក់របស់កម្មករនិយោជិតអាចមានលក្ខណៈ និងស្ថានភាពផ្សេងៗពីគ្នា ហើយមានចំណុចខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ដែលវាអាចធ្វើឲ្យគ្រោះថ្នាក់នេះ ជាគ្រោះថ្នាក់ការងារ ឬមិនមែនជាគ្រោះថ្នាក់ការងារ។ ចំណុចសំខាន់ដែលត្រូវស្វែងរកថា គ្រោះថ្នាក់មួយជាគ្រោះថ្នាក់ការងារ គឺត្រូវធ្វើការស្វែងរកអំពីទំនាក់ទំនង ឬចំណងរវាងគ្រោះថ្នាក់នោះជាមួយនឹងការងារ ហើយធ្វើការពិចារណាថាបើចំណង និងទំនាក់ទំនងនោះវាស្របនឹងធាតុសំខាន់ៗ ដែលមានចែងនៅក្នុងច្បាប់ ឬមានហេតុផលសមរម្យទេ។

### ៣.៣.២. ការទទួលបានតាវកាលិក

ដើម្បីទទួលបានតាវកាលិកពី ប.ស.ស កម្មករនិយោជិតដែលជាជនរងគ្រោះត្រូវបង្ហាញភស្តុតាងជូន ប.ស.ស។ ក្នុងករណីដែល ប.ស.ស យល់ឃើញថាការបង្ហាញនោះពិតជាត្រឹមត្រូវអាចទទួលយកបាន ហើយស្របតាមអ្វីដែលច្បាប់បានកំណត់ ប.ស.ស និងផ្តល់ជាតាវកាលិកជូនតាមច្បាប់កំណត់។ ករណីដែលមានការក្លែងបន្លំ ភស្តុតាង ឯកសារពាក់ព័ន្ធដើម្បីទទួលបានតាវកាលិកសម្រាប់ខ្លួន ឬតតិយជន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៦០ថ្ងៃ ទៅ៩០ថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ និងត្រូវមានទោសជាប់ពន្ធនាគារពី០៦ថ្ងៃ ទៅ០១ខែ ឬក៏ត្រូវផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរនេះ ដោយមិនគិតដល់ទោសដទៃទៀត[38]។

#### ៣.៣.២.១. សិទ្ធិទទួលបានតាវកាលិក

កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបានតាវកាលិក នៅពេលដែលសាមីជនទទួលរងហានិភ័យការងារ។ តាវកាលិកនេះគឺជាបន្ទុករបស់ ប.ស.ស។

---

[37] មាត្រា១៣ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[38] មាត្រា៣៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់បទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

### ៣.៣.២.២. ការជូនដំណឹងហានិភ័យការងារ

នៅពេលមានហានិភ័យការងារកើតឡើង ដើម្បីទទួលបានតាវកាលិកពី ប.ស.ស កម្មករនិយោជិត និងនិយោជកមានកាតព្វកិច្ចរៀងៗខ្លួន។ កម្មករនិយោជិត ជាសមាជិក ប.ស.ស ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាងនិយោជក អំពីហានិភ័យការងារ (គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជម្ងឺវិជ្ជាជីវៈ) ដែលធ្លាក់មកលើខ្លួន យ៉ាងយូរបំផុត **២៤ម៉ោង** បន្ទាប់ពីឧបទ្ទវហេតុនោះកើតឡើង លើកលែងតែក្នុងករណីប្រធានសក្តិ ឬការមិនមានលទ្ធភាពជាស្ថាពរ ឬក៏មិនមានមូលហេតុសមហេតុសមផល។ ករណីកម្មករនិយោជិតរងគ្រោះថ្នាក់ការងារមិនអាចជូនដំណឹងដោយផ្ទាល់មកនិយោជករបស់ខ្លួនបាន ការជូនដំណឹងពីគ្រោះថ្នាក់ការងារនេះអាចធ្វើឡើងដោយតំណាងកម្មករនិយោជិត ឬប្រធានក្រុមរបស់ខ្លួន។ ក្នុងករណីនេះតំណាងកម្មករនិយោជិត ឬប្រធានក្រុមត្រូវធ្វើលិខិតជូនដំណឹងនេះទៅនិយោជក ឬអ្នកតំណាងនិយោជក ព្រមទាំងចម្លងលិខិតនេះជូនទៅនាយកដ្ឋានសន្តិសុខសង្គម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុងផង។ កាតព្វកិច្ចដូចគ្នានេះដែរ ក្នុងករណីដែលមានគ្រោះថ្នាក់បណ្តាលឲ្យបាត់បង់ជីវិត កាតព្វកិច្ចនៃការជូនដំណឹងនេះត្រូវធ្លាក់លើសិទ្ធិវន្ត[39]របស់ជនរងគ្រោះ។

ចំណែកនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ហើយដែលបានចុះបញ្ជិកានៅក្នុង ប.ស.ស ត្រូវជូនដំណឹងទៅ ប.ស.ស ក្នុងរយៈពេលយ៉ាងយូរបំផុត **៤៨ម៉ោង** នៃថ្ងៃធ្វើការបន្ទាប់ពីទទួលដំណឹងហានិភ័យការងារដែលធ្លាក់មកលើកម្មករនិយោជិតរបស់ខ្លួន[40]។ ក្នុងករណីជាគ្រោះថ្នាក់ការងារ ត្រូវធ្វើបាយការណ៍តាមទម្រង់របាយការណ៍ហានិភ័យការងារ[41] ភ្ជាប់ជាមួយឯកសារពាក់ពន្ធ័ តាមរយៈសារអេឡិចត្រូនិចbenefit.nssf.gov.kh។

មួយវិញទៀត ការជូនដំណឹងនេះត្រូវធ្វើទៅនាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងការងារ បើសហគ្រាស គ្រឹះស្ថានមានទីតាំងនៅក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែចំពោះសហគ្រាសដែលមានទីតាំងនៅខេត្ត ឬក្រុងដទៃទៀត និយោជក ឬម្ចាស់សហគ្រាសនោះត្រូវប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារទៅមន្ទីរការងារនៃខេត្ត ឬក្រុងដែលសហគ្រាសនោះតាំងនៅ។

[39]មានន័យថា អ្នកមានសិទ្ធិលើវត្ថុណាមួយ (វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ រៀបរៀងដោយសមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ)

[40]ប្រការ១ នៃប្រកាសរួមលេខ ១១០ កប/ប្រក ស្តីពីការជូនហានិភ័យការងារថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ២០០៨

[41]ប្រការ២ នៃប្រកាសរួមលេខ ១១០ កប/ប្រក ស្តីពីការជូនហានិភ័យការងារថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ២០០៨

ការជូនដំណឹងពីហានិភ័យការងារទៅ ប.ស.ស ពិតជាមានសារៈសំខាន់ណាស់សម្រាប់កម្មករនិយោជិតដែលរងគ្រោះ ព្រោះការជូនដំណឹងកាន់តែឆាប់រហ័ស ដំណើរការនៃការអង្កេតគ្រោះថ្នាក់ការងារកាន់តែបានឆាប់ ហើយប្រសិនកម្មករនិយោជិតទទួលរងហានិភ័យការងារមែន ប.ស.ស ក៏អាចជួយសង្គ្រោះជនរងគ្រោះបានឆាប់រហ័ស ហើយអាចផ្តល់អត្ថប្រយោជន៍បន្ថែមទៀតជូនជនរងគ្រោះបានផងដែរ។

**៣.៣.២.៣. ការអង្កេតហានិភ័យការងារ**

បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារហើយ មុននឹងផ្តល់តាវកាលិកជូនកម្មករនិយោជិតដែលរងគ្រោះ ប.ស.ស ត្រូវមានសមត្ថកិច្ចក្នុងការអង្កេតពីហានិភ័យការងារនោះជាមុនសិន។ ការិយាល័យតាវកាលិក ឬការិយាល័យខេត្ត ក្រុង នៃប.ស.ស ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ។ បន្ទាប់មកអធិការ ឬអភិបាលសន្តិសុខសង្គម ត្រូវធ្វើការអង្កេតពីគ្រោះថ្នាក់ការងារនោះ និងផ្តល់លទ្ធផលនៃករណីនោះមកការិយាល័យតាវកាលិកយ៉ាងឆាប់រហ័សបំផុត។

ចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំការសហការពីអធិការ ឬអភិបាលការងារ។ ប្រសិនបើគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំពត៌មានដែលទាក់ទងនឹងទីកន្លែងពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែងកើតហេតុ។ការចំណាយជាបន្ទុករបស់ ប.ស.ស [42]។

បន្ទាប់ពីអង្កេតរួច ប្រសិនបើជាគ្រោះថ្នាក់ការងារនោះ ប.ស.ស ត្រូវផ្តល់តាវកាលិកហានិភ័យការងារដល់ជនរងគ្រោះ ដូចមានចែងក្នុងប្រកាសស្តីពីតាវកាលិកហានិភ័យការងារ។

**៣.៣.២.៤. តាវកាលិកហានិភ័យការងារដែលត្រូវផ្តល់**

**ក. សេវាសង្គ្រោះបន្ទាន់**

ករណីគ្រោះថ្នាក់ការងារកើតនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់នៅកន្លែងដែលជិតបំផុត បន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយ ប.ស.ស។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់ ប.ស.ស។ ករណីដែលគ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ សាមីជន ឬនិយោជកអាចទាមទារការទូទាត់សងលើការចំណាយសម្រាប់ការសង្គ្រោះពី ប.ស.ស[43]។ ការអនុវត្តចំពោះ

[42]ប្រការ៣ នៃប្រកាសលេខ១០៩ កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

[43]ប្រការ៤ នៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

ការសង្គ្រោះបន្ទាន់ មានន័យថាជាការសង្គ្រោះចំពោះជនរងគ្រោះថ្នាក់ការងារដែលបណ្តាលឲ្យរងរបួសហូរឈាមច្រើនមិនអាចឃាត់ឈាមបាន ឬការប៉ះទង្គិចបណ្តាលឲ្យស្លាប់ ឬឧបទ្ទវហេតុដទៃទៀតដែលជាធម្មតាគិលានសង្គ្រោះនៅក្នុងសហគ្រាស គ្រឹះស្ថានផ្ទាល់មិនអាចជួយបាន ហើយចាំបាច់ត្រូវតែសង្គ្រោះឲ្យទាន់ពេលវេលា ពុំនោះសោតនឹងនាំឲ្យជនរងគ្រោះអាចបាត់បង់ជីវិត ឬទទួលពិការភាពដោយសារការព្យាបាលយឺតពេល។ ករណីនេះ និយោជក ឬអ្នកតំណាង ឬញាតិមិត្តជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលណា ដែលស្ថិតនៅជិតកន្លែងកើតហេតុបំផុតដើម្បីធ្វើការសង្គ្រោះបន្ទាន់[44]។

សោហ៊ុយសង្គ្រោះបន្ទាន់នេះ ប.ស.ស នឹងទូទាត់សងវិញ បន្ទាប់ពីទទួលបានការទាមទារពីជនរងគ្រោះ ឬអ្នកតំណាងដោយមានវិក្កយបត្រ ស្របតាមវេជ្ជបញ្ជាព្រមទាំងមានសរសេរតម្លៃលំអិតពីមុខចំណាយនីមួយៗឲ្យបានច្បាស់លាស់ និងឯកសារភ្ជាប់ផ្សេងៗជាភស្តុតាងត្រឹមត្រូវជាច្បាប់ដើម ដែលចេញដោយមន្ទីរពេទ្យ ឬកន្លែងព្យាបាលឯកជនដែលទទួលការសង្គ្រោះនោះ។

### ខ. សេវាថែទាំ និងព្យាបាល

ការព្យាបាលចំពោះកម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារត្រូវតែធ្វើឡើងនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយ ប.ស.ស។ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបានការពិនិត្យព្យាបាល ការសម្រាកព្យាបាល នៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយ ប.ស.ស ផ្អែកលើកិច្ចព្រមព្រៀងរវាង ប.ស.ស និងមន្ទីរពហុព្យាបាល។ ករណីគ្រូពេទ្យព្យាបាលតម្រូវឲ្យទិញឱសថ ឬសម្ភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលពុំមានចែងក្នុងកិច្ចព្រមព្រៀង ប.ស.សអាចទូទាត់សងជនរងគ្រោះ ឬអ្នកតំណាងវិញបាន លុះត្រាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ។ ករណីដែលជនរងគ្រោះបានព្យាបាល ក្រៅពីគិលាននុដ្ឋាននៅក្នុងសហគ្រាស គ្រឹះស្ថាន ឬនៅក្រៅមន្ទីរពេទ្យ ដែលបានចុះកិច្ចសន្យាជាមួយ ប.ស.ស នោះប.ស.ស នឹងទូទាត់សងវិញតាមតារាងតម្លៃរបស់មន្ទីរពេទ្យដែលប.ស.សបានចុះកិច្ចសន្យាជាមួយ[45]។

នៅពេលមានហានិភ័យការងារកើតឡើង ជនរងគ្រោះ និងនិយោជកអាចធ្វើការទំនាក់ទំនងទៅមន្ទីរពេទ្យដូចខាងក្រោម ដើម្បីទទួលបានការសម្របសម្រួលសេវាព្យាបាលពីភ្នាក់ងាររបស់ ប.ស.ស ដែលប្រចាំការនៅមន្ទីរពេទ្យទាំងនេះ៖

[44]សេចក្តីជូនដំណឹងលេខ ០១/០៩ ប.ស.ស/សជណ ចុះថ្ងៃទី ១៨/០១/២០០៩ របស់បេឡាជាតិរបបសន្តិសុខសង្គម

[45]ប្រការ៥ នៃប្រកាសលេខ១០៩ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

១.មន្ទីរពេទ្យកាល់ម៉ែត

២.មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត

៣.មន្ទីរពេទ្យជ័យជំនះ(កណ្តាល)

៤.មន្ទីរពេទ្យព្រះកុសុមៈ[46]

**គ. ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាចំនួនទឹកប្រាក់ដែលបង្ហាញថាកម្មករនិយោជិតអាចរកជាមធ្យមបានប្រាក់ឈ្នួលប៉ុន្មានក្នុងមួយថ្ងៃ។ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល ៦ខែមុនកាលបរិច្ឆេទនៃហានិភ័យការងារ។ រីឯប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យមនឹង ៣០ថ្ងៃ[47]។

- **រូបមន្តគណនា**

**ប្រាក់ឈ្នួលមធ្យម = ប្រាក់ឈ្នួលជាប់ភាគទាន (៦ខែចុងក្រោយមុនគ្រោះថ្នាក់ការងារ)/៦ (ខែ)**
**ប្រាកឈ្នួលមធ្យមប្រចាំថ្ងៃ = ប្រាក់ឈ្នួលមធ្យម / ៣០ (ថ្ងៃ)**

ចំពោះប្រាក់ឈ្នួលជាប់ភាគទាន ត្រូវបានកម្រិតដូចខាងក្រោម[48]៖

| ថ្នាក់ | ចំនួនប្រាក់សរុប (រៀល) | ប្រាក់ឈ្នួលជាប់ភាគទាន (រៀល) |
|---|---|---|
| ១ | តិចជាង ២០០.០០០ | ២០០.០០០ |
| ២ | ២០០.០០១-២៥០.០០០ | ២២៥.០០០ |
| ៣ | ២៥០.០០១-៣០០.០០០ | ២៧៥.០០០ |
| ៤ | ៣០០.០០១-៣៥០.០០០ | ៣២៥.០០០ |
| ៥ | ៣៥០.០០១-៤០០.០០០ | ៣៧៥.០០០ |
| ៦ | ៤០០.០០១-៤៥០.០០០ | ៤២៥.០០០ |
| ៧ | ៤៥០.០០១-៥០០.០០០ | ៤៧៥.០០០ |

46 សេចក្តីជូនដំណឹងលេខ ០៩/០៩កប/សជណ ចុះថ្ងៃទី២៥-០៩-២០០៩ ស្តីពីវិសាលភាពរបបធានារ៉ាប់រងហានិភ័យការងារ

47 ប្រការ៦ នៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

48 ឧបសម្ព័ន្ធ១ នៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

| | | |
|---|---|---|
| ៨ | ៥០០.០០១-៥៥០.០០០ | ៥២៥.០០០ |
| ៩ | ៥៥០.០០១-៦០០.០០០ | ៥៧៥.០០០ |
| ១០ | ៦០០.០០១-៦៥០.០០០ | ៦២៥.០០០ |
| ១១ | ៦៥០.០០១-៧០០.០០០ | ៦៧៥.០០០ |
| ១២ | ៧០០.០០១-៧៥០.០០០ | ៧២៥.០០០ |
| ១៣ | ៧៥០.០០១-៨០០.០០០ | ៧៧៥.០០០ |
| ១៤ | ៨០០.០០១-៨៥០.០០០ | ៨២៥.០០០ |
| ១៥ | ៨៥០.០០១-៩០០.០០០ | ៨៧៥.០០០ |
| ១៦ | ៩០០.០០១-៩៥០.០០០ | ៩២៥.០០០ |
| ១៧ | ៩៥០.០០១-១.០០០.០០០ | ៩៧៥.០០០ |
| ១៨ | ១.០០០.០០០ឡើង | ១.០០០.០០០ |

**ឧទាហរណ៍៖** កញ្ញា **គន្ធា** គឺជាកម្មការនីរោងចក្រម្នាក់នៅខេត្តកំពង់ស្ពឺ។ នៅខែសីហាឆ្នាំ២០១៣ គាត់បានជួបប្រទះហានិភ័យការងារ ហើយប្រាក់ឈ្នួលដែលគាត់ទទួលបានក្នុងរយៈពេល៦ខែចុងក្រោយមុនកាលបរិច្ឆេទគ្រោះថ្នាក់នេះគឺ៖

| **ខែ** | **ប្រាក់ឈ្នួល (រៀល)** | **ប្រាក់ឈ្នួលជាប់ភាគទាន (រៀល)** |
|---|---|---|
| កុម្ភៈ | ៤១៥.០០០ | ៤២៥.០០០ |
| មិនា | ៤៣០.៥០០ | ៤២៥.០០០ |
| មេសា | ៤៨៥.០០០ | ៤៧៥.០០០ |
| ឧសភា | ៥១០.០០០ | ៥២៥.០០០ |
| មិថុនា | ៥០៥.០០០ | ៥២៥.០០០ |
| កក្កដា | ៥៥០.០០០ | ៥២៥.០០០ |
| សរុប | **២.៨៩៥.៥០០** | **២.៩០០.០០០** |

**គណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

យើងបាន៖ ប្រាក់ឈ្នួលមធ្យម = ២.៩០០.០០០ / ៦ = ៤៨៣.៣៣៣

ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ = ៤៨៣.៣៣៣ / ៣០ = ១៦.១១១

ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់កញ្ញាគន្ធាគឺ **១៦.១១១រៀល**

**ឃ. តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន**

ពេលដែលបុគ្គលម្នាក់ គ្មានសមត្ថភាពបំពេញការងារជាធម្មតាដូចដែលគាត់ធ្លាប់បានបំពេញដោយសារតែគាត់បាត់បង់សមត្ថភាព ឬមានភាពមិនប្រក្រតីផ្នែកសរីរាង្គ ឬផ្នែកណាមួយនៃរាងកាយ ហើយតម្រូវឲ្យគាត់ត្រូវសម្រាកព្យាបាលក្នុងពេលវេលាបណ្តោះអាសន្នមួយដោយទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ករណីនេះហៅថា **ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន។** ពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវបានកំណត់ រយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជម្ងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល និងរយៈពេលនៃការសម្រាកក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា[49]។

កម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារ មានសិទ្ធិទទួលបានតាវកាលិកពីបេឡាជាតិរបបសន្តិសុខសង្គម ដែលរួមមានប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃគ្រោះថ្នាក់ការងារ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែរក្សាជនរងគ្រោះ ក្នុងរយៈពេលសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល[50]។ ប្រាក់ឈ្នួលផ្អាកការងារដំបូងរបស់ជនរងគ្រោះថ្នាក់ការងារ ត្រូវនៅក្នុងបន្ទុករបស់និយោជក មានន័យថា ករណីជនរងគ្រោះថ្នាក់ការងារត្រូវសម្រាកព្យាបាលចំនួន៤ថ្ងៃ នោះគាត់នឹងទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ថ្ងៃទី១ ពីនិយោជក រីឯថ្ងៃទីពីរ បី បួន ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវស្មើនឹង ៧០ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ។ ចំពោះអ្នកដែលថែទាំនៅមន្ទីរពេទ្យក៏អាចទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃដែរ ពោលគឺស្មើនឹង៥០ភាគរយនៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់

[49] ចំណុច៧.១ ក្នុងប្រការ៧ នៃប្រកាសលេខ១៤០កប/ប្រ.ក ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ១០៩កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

[50] ចំណុច៧.២ ក្នុងប្រការ៧ នៃប្រកាសលេខ១៤០កប/ប្រ.ក ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ១០៩កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

ជនរងគ្រោះ[51]។ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវផ្តល់ជូនជនរងគ្រោះរហូតដល់មុខរបួសជាសះស្បើយ។

- **រូបមន្ត**

**ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ជនរងគ្រោះ = ៧០% x ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

**ប្រាក់បំណាច់ប្រចាំថ្ងៃរបស់អ្នកថែទាំអ្នកជម្ងឺ = ៥០% x ប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ**

**ឧទាហរណ៍៖** លោកសុខ បានទទួលរងហានិភ័យការងារ ដែលតម្រូវឲ្យគាត់សម្រាកព្យាបាលរយៈពេល ០៦ថ្ងៃ។ ប្រាក់ឈ្នួលរបស់គាត់គឺ ៥៥០.០០០រៀល ក្នុងមួយខែនៅក្នុងរយៈពេល៦ខែចុងក្រោយមុនពេលគាត់ជួបគ្រោះថ្នាក់នេះ។

តើគាត់អាចទទួលបានប្រាក់បំណាច់សរុបប៉ុន្មាន?

**ចម្លើយ ៖** គណនាប្រាក់បំណាច់សរុប

ប្រសិនបើប្រាក់ឈ្នួលរបស់គាត់ ៥៥០.០០០រៀល ក្នុងខែនីមួយៗថេរ ក្នុងកំឡុងពេល៦ខែមុនគ្រោះថ្នាក់ការងារ នោះប្រាក់ឈ្នួលជាប់ភាគទានរបស់គាត់គឺ៖

៥២៥.០០០ x ៦= **៣.១៥០.០០០រៀល**

ប្រាក់ឈ្នួលមធ្យមរបស់គាត់ក្នុងរយៈពេល ៦ខែចុងក្រោយគឺ៖

៣១៥០០០០ / ៦ = **៥២៥.០០០រៀល**

**គណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

= ៥២៥.០០០រៀល / ៣០ (ថ្ងៃ) = **១៧.៥០០រៀល**

**គណនាប្រាក់បំណាច់ប្រចាំថ្ងៃ**

= ០,៧ x ១៧.៥០០រៀល = **១២.២៥០រៀល**

**ដូចនេះ ប្រាក់បំណាច់សរុបដែលគាត់ទទួលបានពី ប.ស.ស សម្រាប់ថ្ងៃទី ២ ៣ ៤ ៥ និង៦ គឺ៖**

= ១២.២៥០រៀល x ៦ (ថ្ងៃ) = **៧៣.៥០០០រៀល**

**ង. តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ គឺជាស្ថានភាពមួយដែល ជនរងគ្រោះមិនអាចរំពឹងថាបានប្រសើរឡើងវិញ។ ការផ្តល់ជូនតាវកាលិក ចំពោះការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍គឺធ្វើឡើងដោយមានការបែងចែកទៅតាមកម្រិតភាគរយ[52]។

[51]ចំណុច៧.៤ ក្នុងប្រការ៧ នៃប្រកាសលេខ១៩០កប/ប្រ.ក ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ១០៩កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

- **ប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០%**

កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង ២០% មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ។ ប្រាក់វិភាជន៍នេះត្រូវផ្តល់ជូនជនរងគ្រោះតែម្តងគត់ ដោយគិតតាមរូបមន្តះ

**វបក = បឈម x កបក x ២០% មតប**

| | | |
|---|---|---|
| វបក | = | វិភាជន៍បាត់បង់សមត្ថភាពការងារ |
| បឈម | = | ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ |
| កបក | = | កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ |
| មតប | = | មេគុណតម្លៃបច្ចុប្បន្ន |

ចំពោះកម្រិតនៃការបាត់បង់សមត្ថភាព និងមេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីហានិភ័យការងារ។

- **ប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី ២០%ឡើងទៅ**

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០%ឡើងទៅ មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវបានកំណត់ដូចខាងក្រោម[53]៖

**ប្រាក់ធនលាភ = បឈម x [ កបក-១/៥កបក ]**

**ឧទាហរណ៍៖** លោក **ឌីណា** គឺជាកម្មករ ដែលបម្រើការងារនៅរោងចក្រដែលថែបមួយកន្លែងតាមបណ្តោយផ្លូវជាតិលេខ៥ គាត់មានអាយុ២៥ឆ្នាំ ហើយគាត់ក៏ជាសមាជិកនៃ ប.ស.ស ផងដែរ។ ថ្ងៃមួយក្នុងកំឡុងពេលបំពេញការងារនៅក្នុងរោងចក្រ គាត់បានជួបប្រទះគ្រោះថ្នាក់ការងារ ដោយ

[52]ចំណុច៨.១ ក្នុងប្រការ៨ នៃប្រកាសលេខ២៣៣កប/ប្រ.ក ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ១០៩កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

[53]ចំណុច៨.២ ក្នុងប្រការ៨ នៃប្រកាសលេខ២៣៣កប/ប្រ.ក ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ១០៩កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

ម៉ាស៊ីនកាត់ដែកធ្វើឲ្យដាច់មេដៃស្តាំរបស់គាត់។ ប្រាក់ឈ្នួលដែលគាត់ទទួលបានក្នុង១ខែ ក្នុងរយៈពេល៦ខែចុងក្រោយមុនគាត់រងគ្រោះថ្នាក់ការងារគឺ ២៥០.០០០រៀល។

តើគាត់ទទួលបានប្រាក់ធនលាភប៉ុន្មាន?

**ដំណោះស្រាយ**

យោងតាមសម្មតិកម្មខាងលើ កម្រិតនៃការបាត់បង់សមត្ថភាពការងាររបស់លោក **ឌីណា** គឺបាត់បង់មេដៃស្តាំ គឺស្មើនឹង ៣០%[54]។

**គណនាប្រាក់ឈ្នួលមធ្យម**

ដោយប្រាក់ឈ្នួលរបស់គាត់ ២៥០.០០០រៀល ក្នុងខែនីមួយៗបានថេរក្នុងកំឡុងពេល ៦ ខែ មុនគ្រោះថ្នាក់ការងារ នាំឲ្យប្រាក់ឈ្នួលជាប់ភាគទានរបស់គាត់គឺៈ

២២៥.០០០ x ៦ = **១.៣៥០.០០០រៀល**

នាំឲ្យប្រាក់ឈ្នួលមធ្យម = ១.៣៥០.០០០ / ៦= ២២៥.០០០រៀល

**គណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ = ២២៥.០០០ / ៣០ =**៧.៥០០រៀល**

**គណនាប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ**

ធល = ៧.៥០០ [៣០% -១/៥ x ៣០% ] = **១.៨០០រៀល**

**ដូចនេះ ប្រាក់ធនលាភដែលលោកឌីណាទទួលបានគឺ ១.៨០០រៀល**

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវបានចាត់ទុកថាជាបណ្តោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គមត្រូវរៀបចំឲ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងាររបស់ជនរងគ្រោះឡើងវិញក្នុងរយៈពេល១ឆ្នាំយ៉ាងយូរ។ ចំពោះជនរងគ្រោះដែលទទួលធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាព តាមកាលកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដែលតម្រូវឲ្យមានអ្នកចាំថែរក្សា ហើយអ្នកដែលថែរក្សានោះមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភស្មើនឹង ៥០%នៃប្រាក់ធនលាភរបស់ជនរងគ្រោះ។

**ច. ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព**

យោងតាមប្រកាសលេខ១០៩ កប/ប្រ.ក ករណីជនរងគ្រោះទទួលហានិភ័យការងាររហូតដល់បាត់បង់ជីវិត អ្នកទទួលរ៉ាប់រងចាត់ចែងក្នុងការរៀបចំបុណ្យសព នឹងទទួលបានប្រាក់

[54]ឧបសម្ព័ន្ធ២ នៃប្រកាសលេខ១០៩កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារាកាលិកហានិភ័យការងារ

វិភាជន៍ជាសោហ៊ុយសម្រាប់បូជាសពចំនួន ១.០០០.០០០ (មួយលាន) រៀល។ ក្រោយមកប្រាក់វិភាជន៍ក៏ត្រូវបានកំណត់ចំនួន ៤.០០០.០០០ (បួនលាន) រៀលវិញ ហើយប្រាក់វិភាជន៍នេះត្រូវតែផ្តល់ជូនដោយផ្ទាល់ ដល់ជនដែលចាត់ចែងបុណ្យសពរបស់ជនរងគ្រោះ[55]។

**ឆ. តាវកាលិកឧត្តរជីវី**

តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឲ្យសិទ្ធិវន្តនៃជនរងគ្រោះ។ ដើម្បីទទួលបានតាវកាលិកឧត្តរជីវី សិទ្ធិវន្តនៃកម្មករនិយោជិត ដែលជាជនរងគ្រោះត្រូវបំពេញលក្ខខណ្ឌចាំបាច់មួយចំនួន ដែលលក្ខខណ្ឌទាំងនោះមានចំណុចផ្សេងៗពីគ្នាទៅតាមសិទ្ធវន្តដែលជា សហព័ទ្ធ ជាកូន ជាឪពុក ម្តាយ ឬជាចាស់ជរានៅក្នុងបន្ទុក។

តាវកាលិកឧត្តរជីវីត្រូវផ្តល់ឲ្យសិទ្ធិវន្តនៃជនរងគ្រោះតាមអត្រា ដូចខាងក្រោម[56]៖

- **ករណីសិទ្ធិវន្តមានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក**

  - **ប្រពន្ធ ឬប្តី = ៣/៥ x ៦៣% បឈម**
  - **ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៦៣% បឈម**
  - **ធនលាភសរុបសម្រាប់មនុស្សចាស់នៅក្នុងបន្ទុក = ៧% បឈម**

- **ករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និង/ ឬកូន**

  - **ប្តី ឬប្រពន្ធ = ៣/៥ x ៧០% បឈម**
  - **ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០% បឈម**

- **ករណីសិទ្ធិវន្តមានតែពុកម្តាយ ឬមនុស្សចាស់ជរា**

  - **ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម**

- **ករណីសិទ្ធិវន្តមានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា**

  - **ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨% បឈម**
  - **ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម**

[55]ប្រការ១០ នៃប្រកាសលេខ២៣៣កប/ប្រ.ក ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ នៃប្រកាសលេខ១០៩កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

[56]ប្រការ១១ នៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

- **ករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា**

  - **ប្តី ឬប្រពន្ធ = ២៨% បឈម**
  - **ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម**

ចំពោះលក្ខខណ្ឌដែលសហាព័ទ្ធត្រូវបំពេញដើម្បីទទួលបានតាវកាលិកឧត្តរជីវី រួមមាន ប្តី ឬប្រពន្ធត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ពោលគឺប្តី ឬប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ និងមានចុះអត្រានុកូលដ្ឋាន មុនពេលមានគ្រោះថ្នាក់ការងារ ឬមុនពេលទទួលមរណភាពដោយគ្រោះថ្នាក់ការងារនៃប្តី ឬប្រពន្ធដែលជាសមាជិក ប.ស.ស[57]។ ប៉ុន្តែសិទ្ធិនេះត្រូវរំលាយ បើប្តី ឬប្រពន្ធនោះរៀបការថ្មី។ ក្នុងករណីរៀបអាពាហ៍ពិពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមកប.ស.ស យ៉ាងយូរបំផុត៣០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ថ្មីរបស់ខ្លួន[58]។

លក្ខខណ្ឌចំពោះកូន ដើម្បីទទួលបានតាវកាលិកឧត្តរជីវីត្រូវតែជាកូននៃសហាព័ទ្ធត្រឹម១៨ឆ្នាំចុះដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងជាកូនដែលបានរៀបអាពាហ៍ពិពាហ៍ ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ករណីមានការលែងលះ ឬករណីមរណភាពនៃប្តី ឬប្រពន្ធ កូននៃអាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍ទី១ដែរ ដោយកូននោះត្រូវមានអាយុ១៨ឆ្នាំចុះដែលមិនទាន់រៀបអាពាហ៍ពិពាហ៍។ ករណីកូនចិញ្ចឹមរបស់សមាជិក ប.ស.ស ស្ថានភាពរបស់កូនចិញ្ចឹម ត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់២១ឆ្នាំ ចំពោះកូនដែលកំពុងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬកូនកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬមានជម្ងឺរ៉ាំរ៉ៃ មិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ឈ្នួល[59]។

លក្ខខណ្ឌចំពោះឪពុក ម្តាយ ឬមនុស្សចាស់ជរា ក្នុងការទទួលបានតាវកាលិករួមមាន ឪពុកម្តាយ ឬមនុស្សចាស់ជរាត្រូវស្ថិតនៅក្រោមបន្ទុកផ្ទាល់របស់ជនរងគ្រោះដែលស្លាប់[60] ឬត្រូវបានរស់នៅជាមួយជនរងគ្រោះមុនពេលជនរងគ្រោះស្លាប់។

---

[57]មាត្រា៣៤នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[58]ប្រការ១១ នៃប្រកាសលេខ ១០៩ កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ

[59]មាត្រា៣៤នៃអនុក្រឹត្យលេខ ១៦អនក្រ.បក ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[60]មាត្រា៣៤ ចំនុច(គ)នៃអនុក្រឹត្យលេខ ១៦អនក្រ.បក ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

**ជ. សេវាបុនរ្និតិសម្បទា**

កម្មករនិយោជិត ដែលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យដែលទទួលស្គាល់ដោយ ប.ស.ស។ កម្មករនិយោជិត ដែលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាសម្របសម្រួលការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**៣.៣.៣. ការទាមទារតាវកាលិក**

ការទាមទារតាវកាលិក សម្រាប់ការថែទាំ និងព្យាបាលអាចត្រូវធ្វើឡើងដោយមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលជនរងគ្រោះ ឬនិយោជក ឬកម្មករនិយោជិតដែលជាជនរងគ្រោះផ្ទាល់តាមទម្រង់ **តាវកាលិកថែទាំ និងព្យាបាល** ឬហៅថា ទម្រង់ ៣.០២[61]។

ចំពោះការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវធ្វើដោយជនរងគ្រោះ ឬតំណាងតាមទម្រង់៣.០៣[62]បែបបទនៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយវេជ្ជបញ្ជា និងលិខិតបញ្ជាក់គ្រូពេទ្យព្យាបាលជាផ្លូវការ។

ការទាមទារតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ **តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍** ឬហៅថាទម្រង់ ៣.០៤[63]។ ប្រសិនបើជនរងគ្រោះមិនអាចមានសមត្ថភាពក្នុងការទាមទារតាវកាលិកបាន ដោយសារតែស្ថានភាពនៃការបាត់បង់សមត្ថភាពធ្ងន់ធ្ងរ ការទាមទារត្រូវធ្វើដោយអ្នកតំណាងជនរងគ្រោះ អ្នកតំណាងអាចជាប្តី ប្រពន្ធ កូន ឬជនដែលមានភារៈថែរក្សាជនរងគ្រោះ។

ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬអ្នកតំណាងតាមទម្រង់**តាវកាលិកឧត្តរជីវី** ឬហៅទម្រង់៣.០៥ និងទម្រង់**វិភាជន៍បូជាសព** ឬទម្រង់៣.០៦[64] ។

[61]ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
[62]ឧបសម្ព័ន្ធ៥ នៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
[63]ឧបសម្ព័ន្ធ៦ នៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
[64]ឧបសម្ព័ន្ធ៧ និង៨ នៃប្រកាសលេខ១០៩កប/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

សិទ្ធិក្នុងការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល១ឆ្នាំ។ រីឯសិទ្ធិក្នុងការទាមទារប្រាក់ធនលាភ ត្រូវអស់សុពលភាពត្រឹមរយៈពេល ៥ឆ្នាំ។

# ជំពូកទី៣

# របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

# នៃបេឡាជាតិរបបសន្តិសុខសង្គម

# ជំពូកទី៣
# របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនៃបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព។ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព គឺជាជំហានបន្ទាប់របស់បេឡាជាតិរបបសន្តិសុខសង្គម បន្ទាប់ពីទទួលបានជោគជ័យលើការអនុវត្តជំហានទីមួយផ្នែកហានិភ័យការងារកន្លងមក។ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពត្រូវបង្កើតឡើងដោយអនុក្រឹត្យ លេខ០១អនក្រ.បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ។ ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនេះ គឺដើម្បីផ្តល់ឲ្យសមាជិក ប.ស.ស នូវសេវា និងតាវកាលិកព្យាបាល និងថែទាំវេជ្ជសាស្ត្រ, ផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជម្ងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាពជាដើម[65]។

ដើម្បីយល់កាន់តែច្បាស់អំពី របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព យើងខ្ញុំនឹងធ្វើការបកស្រាយ ដោយផ្តោតសំខាន់លើ៖

- វិសាលភាពនៃការអនុវត្ត និងការបង់ភាគទានផ្នែកថែទាំសុខភាព
- តាវកាលិកផ្នែកថែទាំសុខភាព
- ការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាព

## ៣.១. វិសាលភាពនៃការអនុវត្ត និងការបង់ភាគទានផ្នែកថែទាំសុខភាព

### ៣.១.១. ដំណាក់កាលអនុវត្ត

របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពត្រូវបានអនុវត្តចំពោះកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុងផ្នែកថែទាំសុខភាព។ ចំពោះជំហាននៃការអនុវត្តផ្នែកថែទាំសុខភាពនេះ ត្រូវធ្វើតាមដំណាក់កាលដូចខាងក្រោម[66]៖

[65]មាត្រា២ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[66]ប្រការ២ នៃប្រកាសលេខ ០៩៣/១៦ ក.ប/ប្រ.ក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៦

- ដំណាក់កាលដំបូងត្រូវអនុវត្តចំពោះសមាជិក ប.ស.ស ដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាព ជនរងគ្រោះថ្នាក់ការងារដែលបានបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងឧត្តរជីវី[67]។
- ដំណាក់កាលបន្ទាប់ ត្រូវអនុវត្តចំពោះអ្នកនៅក្នុងបន្ទុកនៃសមាជិក ប.ស.ស ដែលរួមមានប្រពន្ធ ឬប្តី និងកូន។

ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនេះ ត្រូវចាប់ផ្តើមចេញពីសហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងភូមិសាស្រ្តនៃរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងជាបន្តបន្ទាប់ឆ្ពោះទៅកាន់ខេត្តដទៃទៀត ស្របតាមស្ថានភាពបច្ចេកទេស និងភូមិសាស្រ្តជាក់ស្តែង[68]។

ចំពោះសហគ្រាស គ្រឹះស្ថានណាដែលបេឡាជាតិរបបសន្តិសុខសង្គមពុំទាន់បានចុះបញ្ជិកាក្នុងផ្នែកថែទាំសុខភាព ត្រូវបន្តអនុវត្តទៅតាមអនុសញ្ញារួម បទបញ្ជាផ្ទៃក្នុងស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររហូតដល់មានការចុះបញ្ជិកាពី ប.ស.ស[69]។

### ៣.១.២. កាលបរិច្ឆេទអនុវត្ត

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ ដោយការអនុវត្តនេះត្រូវធ្វើលើកម្មករនិយោជិត ដែលបំពេញការងារនៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការបបថែទាំសុខភាព ក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

### ៣.១.៣. ការបង់ភាគទានថែទាំសុខភាព

#### ៣.១.៣.១. កាតព្វកិច្ចបង់ភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្រោមច្បាប់ស្តីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាព។ មិនត្រឹមតែនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទេដែលមានកាតព្វកិច្ចត្រូវបង់ភាគទាន កម្មករ

[67] សំដៅដល់អ្នកនៅរស់មានជីវិតជាប្រពន្ធ ឬប្តី និងកូន ចៅក្នុងបន្ទុកផ្ទាល់នៃសាមីជន ដែលជាសមាជិក ប.ស.សក្រោយពីទទួលមរណភាពដោយហានិភ័យការងារ (ប្រការ២ នៃប្រកាសលេខ ២២០ ក.ប/ប្រ.ក ស្តីពីការកំណត់អត្រាភាគទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦)

[68] ប្រការ៣ នៃប្រកាសលេខ ០៩៣/១៦ ក.ប/ប្រ.ក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៦

[69] ប្រការ៤ នៃប្រកាសលេខ ០៩៣/១៦ ក.ប/ប្រ.ក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៦

និយោជិតក៏មានកាតព្វកិច្ចក្នុងការបង់ភាគទាន ផ្នែកថែទាំសុខភាពជូនបេឡាជាតិរបបសន្តិសុខសង្គមផងដែរ។ ឧត្តរជីវី ឬជនកំពុងទទួលបានធនលាភ [70] ដោយការបាតបង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាព។

ចំពោះកម្មករនិយោជិត ដែលធ្វើការពីរកន្លែង ឬច្រើនកន្លែងហើយបានបង់ភាគទានចំណែករបស់សាមីជនដែលលើសចំនួនកំណត់ បេឡាជាតិរបបសន្តិសុខសង្គមត្រូវបង្វិលជូនសាមីជនវិញរៀងរាល់ដំណាច់ឆ្នាំចំពោះចំណែកដែលលើសនេះ។

### ៣.១.៣.២. អត្រាភាគទាន

អត្រាភាគទានផ្នែកថែទាំសុខភាព ដែលជាបន្ទុករបស់និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថានត្រូវកំណត់ស្មើនឹង ១,៣ភាគរយ នៃប្រាក់ឈ្នួលមធ្យម ក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។ រីឯអត្រាភាគទានផ្នែកថែទាំសុខភាព ដែលជាបន្ទុករបស់កម្មករនិយោជិត ត្រូវកំណត់ស្មើនឹង ១,៣ភាគរយ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

ចំពោះអត្រាភាគទាន ដែលជាបន្ទុករបស់ឧត្តរជីវី ឬជនកំពុងទទួលបានប្រាក់ធនលាភ ត្រូវកំណត់ស្មើនឹង ១,៣ភាគរយនៃតាវកាលិករបស់សាមីខ្លួន។ ប្រាក់ឈ្នួលមធ្យមប្រចាំខែក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតសម្រាប់ផ្នែកថែទាំសុខភាព ត្រូវបានកំណត់ដូចគ្នានឹងប្រាក់ឈ្នួលមធ្យម ក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតសម្រាប់ផ្នែកហានិភ័យការងារ។

ករណីសហគ្រាស គ្រឹះស្ថានបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតរបស់ខ្លួនជារូបិយប័ណ្ណបរទេស នោះប្រាក់ឈ្នួលមធ្យមប្រចាំខែត្រូវគិតជាប្រាក់រៀលតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា [71] ។ អត្រាភាគទានផ្នែកថែទាំសុខភាព អាចនឹងត្រូវកំណត់សារជាថ្មីដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

[70] ប្រាក់ដែលឧបត្ថម្ភដល់ជនបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដោយសារហានិភ័យការងារចាប់ពី ២០%ឡើងទៅ

[71] ប្រការ៣ នៃប្រកាសលេខ ២២០ ក.ប/ប្រ.ក ស្តីពីការកំណត់អត្រាភាគទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦

# តារាងភាគទានផ្នែកថែទាំសុខភាព

| ថ្នាក់ | ប្រាក់ឈ្នួលប្រចាំខែ (គិតជារៀល) | ប្រាក់ឈ្នួលមធ្យមប្រចាំខែ (គិតជារៀល) | ភាគទានជាបន្ទុកកម្មករនិយោជិត ១នាក់ (១.៣%) | ភាគទានជាបន្ទុកនិយោកសម្រាប់កម្មករនិយោជិត ១នាក់ (១.៣%) | ភាគទានសរុប |
|---|---|---|---|---|---|
| ១ | តិចជាង ២០០.០០០ | ២០០.០០០ | ២.៦០០ | ២.៦០០ | ៥.២០០ |
| ២ | ២០០.០០១ -២៥០.០០០ | ២២៥.០០០ | ២.៩២៥ | ២.៩២៥ | ៥.៨៥០ |
| ៣ | ២៥០.០០១ -៣០០.០០០ | ២៧៥.០០០ | ៣.៥៧៥ | ៣.៥៧៥ | ៧.១៥០ |
| ៤ | ៣០០.០០១ -៣៥០.០០០ | ៣២៥.០០០ | ៤.២២៥ | ៤.២២៥ | ៨.៤៥០ |
| ៥ | ៣៥០.០០១ -៤០០.០០០ | ៣៧៥.០០០ | ៤.៨៧៥ | ៤.៨៧៥ | ៩.៧៥០ |
| ៦ | ៤០០.០០១ -៤៥០.០០១ | ៤២៥.០០០ | ៥.៥២៥ | ៥.៥២៥ | ១១.០៥០ |
| ៧ | ៤៥០.០០១ -៥០០.០០០ | ៤៧៥.០០០ | ៦.១៧៥ | ៦.១៧៥ | ១២.៣៥០ |
| ៨ | ៥០០.០០១ -៥៥០.០០០ | ៥២៥.០០០ | ៦.៨២៥ | ៦.៨២៥ | ១៣.៦៥០ |
| ៩ | ៥៥០.០០១ -៦០០.០០០ | ៥៧៥.០០០ | ៧.៤៧៥ | ៧.៤៧៥ | ១៤.៩៥០ |
| ១០ | ៦០០.០០១ -៦៥០.០០០ | ៦២៥.០០០ | ៨.១២៥ | ៨.១២៥ | ១៦.២៥០ |
| ១១ | ៦៥០.០០១ -៧០០.០០០ | ៦៧៥.០០០ | ៨.៧៧៥ | ៨.៧៧៥ | ១៧.៥៥០ |
| ១២ | ៧០០.០០១ -៧៥០.០០០ | ៧២៥.០០០ | ៩.៤២៥ | ៩.៤២៥ | ១៨.៨៥០ |
| ១៣ | ៧៥០.០០១ -៨០០.០០០ | ៧៧៥.០០០ | ១០.០៧៥ | ១០.០៧៥ | ២០.១៥០ |
| ១៤ | ៨០០.០០១ -៨៥០.០០០ | ៨២៥.០០០ | ១០.៧២៥ | ១០.៧២៥ | ២១.៤៥០ |
| ១៥ | ៨៥០.០០១ -៩០០.០០០ | ៨៧៥.០០០ | ១១.៣៧៥ | ១១.៣៧៥ | ២២.៧៥០ |
| ១៦ | ៩០០.០០១- ៩៥០.០០០ | ៩២៥.០០០ | ១២.០២៥ | ១២.០២៥ | ២៤.០៥០ |
| ១៧ | ៩៥០.០០១ -១.០០០.០០០ | ៩៧៥.០០០ | ១២.៦៧៥ | ១២.៦៧៥ | ២៥.៣៥០ |
| ១៨ | ១.០០០.០០១ឡើង | ១.០០០.០០០ | ១៣.០០០ | ១៣.០០០ | ២៦.០០០ |

- **រូបមន្តអត្រាភាគទានផ្នែកថែទាំសុខភាពជាបន្ទុកកម្មករនិយោជិត**

**ភាគទានជាបន្ទុកកម្មករនិយោជិត = ប្រាក់ឈ្នួលមធ្យមប្រចាំខែរបស់កម្មករនិយោជិត x ១,៣ភាគរយ (០,០១៣)**

- **រូបមន្តអត្រាភាគទានផ្នែកថែទាំសុខភាពជាបន្ទុកនិយោជកសម្រាប់កម្មករនិយោជិត**

| |
|---|
| **ភាគទានជាបន្ទុកនិយោជក = ប្រាក់ឈ្នួលមធ្យមប្រចាំខែរបស់កម្មករនិយោជិត x ១,៣ភាគរយ (០,០១៣)** |

**ឧទាហរណ៍៖**

១. កម្មករនិយោជិត មានប្រាក់ឈ្នួលប្រចាំខែតិចជាង ២០០.០០០រៀល នោះប្រាក់ឈ្នួលមធ្យមត្រូវកំណត់ស្មើនឹង ២០០.០០០រៀល ក្នុងខែនីមួយៗ នោះយើងអាចទាញបាន ៖

២០០.០០០៛ x ០,០១៣ = **២.៦០០៛ ជាប្រាក់ដែលជាប់ភាគទានប្រចាំខែ**

ដោយក្នុងរបបថែទាំសុខភាព កម្មករនិយោជិត និងនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានសុទ្ធតែមានកាតព្វកិច្ច បង់ភាគទាន ដូចនេះភាគទានសរុបគឺ **២.៦០០ + ២.៦០០ = ៥.២០០រៀល។**

២. កម្មករនិយោជិត មានប្រាក់ឈ្នួលប្រចាំខែចន្លោះពី ២០០.០០១រៀល ទៅ ២៥០.០០០រៀល នោះប្រាក់ឈ្នួលមធ្យមត្រូវកំណត់ស្មើនឹង ២២៥.០០០រៀល ក្នុងខែនីមួយៗ នោះយើងអាចទាញបាន ៖

២២៥.០០០៛ x ០,០១៣ = **២.៩២៥៛ ជាប្រាក់ដែលជាប់ភាគទានប្រចាំខែ**

ដោយក្នុងរបបថែទាំសុខភាព កម្មករនិយោជិត និងនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានសុទ្ធតែមានកាតព្វកិច្ច បង់ភាគទាន ដូចនេះភាគទានសរុបគឺ **២.៩២៥ + ២.៩២៥ = ៥.៨៥០រៀល។**

៣. កម្មករនិយោជិត មានប្រាក់ឈ្នួលប្រចាំខែចន្លោះពី ២៥០.០០១រៀល ទៅ ៣០០.០០០រៀល នោះប្រាក់ឈ្នួលមធ្យមត្រូវ កំណត់ស្មើនឹង ២៧៥.០០០រៀល ក្នុងខែនីមួយៗ នោះយើងអាចទាញបាន ៖

២៧៥.០០០៛ x ០,០១៣ = **៣.៥៧៥៛ ជាប្រាក់ដែលជាប់ភាគទានប្រចាំខែ**

ដោយក្នុងរបបថែទាំសុខភាព កម្មករនិយោជិត និងនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានសុទ្ធតែមានកាតព្វកិច្ច បង់ភាគទាន ដូចនេះភាគទានសរុបគឺ **៣.៥៧៥ + ៣.៥៧៥ = ៧.១៥០រៀល។**

#### ៣.១.៣.៣. កាលបរិច្ឆេទបង់ភាគទាន

ការចាប់ផ្ដើមបង់ភាគទានដំបូងផ្នែកថែទាំសុខភាព ចំពោះសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកា និងការចាប់ផ្ដើមបង់ភាគទានសម្រាប់ឧត្តរជីវី ត្រូវកំណត់ដោយប.ស.ស។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានផ្នែកថែទាំសុខភាពសម្រាប់ខែនីមួយៗជូនដល់បេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់។ និយោជក

ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចប្រមូលភាគទានផ្នែកនេះពីកម្មករនិយោជិត ដោយធ្វើការកាត់ប្រាក់ឈ្នួលតាមចំនួនភាគទានជាក់ស្តែងដែលសាមីជនម្នាក់ៗត្រូវបង់[72]។

ចំពោះបែបបទបង់ភាគទាន សម្រាប់ផ្នែកថែទាំសុខភាព ត្រូវអនុវត្តតាមទម្រង់នៃការបង់ភាគទានដែលកំណត់ដោយបេឡាជាតិរបបសន្តិសុខសង្គម[73]។

## ៣.២. គាវកាលិកផ្នែកថែទាំសុខភាព

តាវកាលិកថែទាំសុខភាព សំដៅដល់របបធានារ៉ាប់រង ដែលផ្តល់កញ្ចប់តាវកាលិកសុខភាព និងសេវាបង្ការដែលបានកំណត់[74]។ តាវកាលិកថែទាំសុខភាព មានជាការផ្តល់កញ្ចប់តាវកាលិកសុខភាព និងសេវាបង្ការសុខភាព។

### ៣.២.១. កញ្ចប់គាវកាលិកសុខភាព

កញ្ចប់តាវកាលិកសុខភាព ត្រូវផ្តល់ឲ្យសមាជិក ប.ស.ស។ កញ្ចប់តាវកាលិកសុខភាព នោះរួមមាន សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ សេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃ។

#### ៣.២.១.១. សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សំដៅដល់សេវាវេជ្ជសាស្ត្រ (សេវាពិគ្រោះជម្ងឺក្រៅ និងសេវាសម្រាកពេទ្យ) សេវាអមវេជ្ជសាស្ត្រ (សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ) និងសេវាជំនួយវេជ្ជសាស្ត្រ (សំដៅដល់ការព្យាបាលដោយស្ពំ ឬដោយចលនា)។

**ក. ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ**

ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យមានសេវាដូចជា៖

- សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ គឺជាការព្យាបាលដែលសំដៅដល់វិធីសាស្ត្រ នៃការធ្វើរោគវិនិច្ឆ័យ ការផ្តល់សេវាថែទាំ ដែលផ្តល់ដោយអ្នកបញ្ចប់ការសិក្សាក្នុងវិស័យសុខាភិបាល ហើយត្រូវបានចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈពេទ្យ និងត្រូវបានអនុញ្ញាតដោយច្បាប់ឲ្យប្រកបមុខរបរតាមវិជ្ជាជីវៈដោយក្រសួងសុខាភិបាល។
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត

[72]ប្រការ៥ នៃប្រកាសលេខ ២២០ ក.ប/ប្រ.ក ស្តីពីការកំណត់អត្រាភាគទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦

[73]ប្រការ៦ នៃប្រកាសលេខ២២០ ក.ប/ប្រ.ក ស្តីពីការកំណត់អត្រាភាគទានសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦

[74]ប្រការ២ នៃប្រកាសលេខ១០៩ក.ប/ប្រ.ក ស្តីពីតាវកាលិកថែទាំសុខភាព ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០១៦

- ឧបករណ៍ផ្នែកសល្យសាស្ត្រ [75] និងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗ ដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់ (ធម្មតា) និងអាហារដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល[76]

**ខ. សេវាពិគ្រោះជម្ងឺក្រៅ**

សេវាពិនិត្យពិគ្រោះជម្ងឺក្រៅ សំដៅដល់សេវាពិនិត្យ និងពិគ្រោះជម្ងឺក្រៅ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ។ សេវាពិគ្រោះជម្ងឺក្រៅមានសេវាដូចជា៖

- សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ រូបភាពវេជ្ជសាស្ត្រ និងពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- បរិក្ខារសល្យសាស្ត្រ និងវេជ្ជសាស្ត្រផ្សេងៗដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

**គ. សេវាសង្គ្រោះបន្ទាន់**

សេវាសង្គ្រោះបន្ទាន់ គឺជាអន្តរាគមន៍ទាំងឡាយណាដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើឡើងភ្លាមក្នុងគោលបំណងជួយសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជម្ងឺ ឬជនរងគ្រោះ។

**ឃ. សេវាព្យាបាលដោយស្ពំ និងដោយចលនា**

សេវាព្យាបាលដោយស្ពំ និងដោយចលនា គឺជាវិធីព្យាបាលមួយប្រភេទដែលត្រូវបានផ្តល់ឲ្យកម្មករនិយោជិត ពេលដែលពួកគេមានការប៉ះទង្គិចក្នុងកម្រិតស្រាល ដែលសេវាទាំងនោះអាចជាការម៉ាស្សា ឬស្ពំដើម្បីបំបាត់ការឈឺចាប់។

**ង. សេវាសម្រាលកូន និងសេវាព្យាបាលថែទាំមុន និងក្រោយពេលសម្រាលកូន**

សមាជិក ប.ស.ស ដែលបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបានសេវាសម្រាលកូន ព្រមទាំងសេវាថែទាំមុន និងក្រោយពេលសម្រាលកូន។

[75]សល្យសាស្ត្រ សំដៅដល់ការវះកាត់តាមរបៀបវិទ្យាសាស្ត្រក្នុងបំណងព្យាបាល

[76]មូលដ្ឋានសុខភាព សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល

**ច. សេវាស្តារនីតិសម្បទា**

សេវាស្តារនីតិសម្បទា គឺជាសេវាដែលការផ្តល់ព្យាបាលថែទាំវេជ្ជសាស្ត្រសម្រាប់របបថែទាំសុខភាពក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬធ្វើឲ្យ ប្រសើរឡើងវិញ នូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬខូចខាតដោយសារជម្ងឺ ការរងរបួស ឬពិការភាព។

**៣.២.១.២. សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសព**

សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសព ត្រូវបានផ្តល់ឲ្យដោយបេឡាជាតិរបបសន្តិសុខសង្គមដល់សមាជិករបស់ខ្លួន ដែលបានជួបប្រទះនូវហានិភ័យផ្សេងៗ ហើយបានគោរពតាមលក្ខខណ្ឌដែលបានកំណត់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

**៣.២.១.៣. ប្រាក់បំណាច់ប្រចាំថ្ងៃ**

ប្រាក់បំណាច់ប្រចាំថ្ងៃ ជាប្រាក់ដែលផ្តល់ជូនដល់កម្មករនិយោជិតសម្រាប់រយៈពេលអាក់ខានការងារដោយសារការធ្លាក់ខ្លួនមានជម្ងឺ គ្រោះថ្នាក់ និងលំហែមាតុភាព។ កម្មករនិយោជិតនឹងទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃទៅតាមភាគរយ និងការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។

**៣.២.២. សេវាបង្ការសុខភាព**

សេវាបង្ការសុខភាព សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់ដទៃទៀត ដើម្បីការពារកុំឲ្យមានបញ្ហាសុខភាពមានជាអាទិ៍ ការស្រាវជ្រាវរកជម្ងឺ ការអប់រំសុខភាព និងកម្មវិធីចាក់ថ្នាំបង្ការ[77]។ សេវាបង្ការសុខភាព ផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម កម្មវិធីជាតិ អង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅនឹងបញ្ហាសុខភាពដទៃទៀត។

ដោយយោងតាមប្រកាសលេខ០៤៩/១៧ កប/ប្រក ប.ស.ស ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការដាក់បញ្ចូលនៃសេវាបង្ការសុខភាពនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព បានកំណត់សេវាបង្ការសុខភាពដូចខាងក្រោម៖

- សេវាចាក់វ៉ាក់សាំងការពារឆ្កែឆ្កួត (Rabies Vaccination)
- សេវាចាក់សេរ៉ូមប្រឆាំងជម្ងឺឆ្កែឆ្កួត (Antirabic Serum)
- សេវាចាក់សេរ៉ូមប្រឆាំងជម្ងឺតេតាណូស (Anti- Tetanus Serum)

[77]ប្រការ២ នៃប្រកាសលេខ១០៩កប/ប្រក ស្តីពីគារកាលិកថែទាំសុខភាព ចុះថ្ងៃទី៧ មិនា ឆ្នាំ២០១៦

- សេវាចាក់សេរ៉ូមប្រឆាំងពិសពស់ (Antivenom Immunoglubulin)
- សេវាពិនិត្យឈាមរកជម្ងឺពកកមាន៖ TSH (Thyroid-Stimulating Hormone) និង Free T3(Free Trilodothyronine), Free T4(Free Thyroxine)
- សេវាពិនិត្យឈាម កំណត់អបោធាតុមហារីក(Cancer Humeraux Marqueurs) ក្រោយការព្យាបាលជម្ងឺមហារីកដោយវះកាត់ និង/ឬក្រោយការព្យាបាលជម្ងឺមហារីកដោយចាក់គីមី និង/ឬក្រោយការព្យាបាលជម្ងឺមហារីកដោយបាញ់កាំរស្មីអ៊ិច មាន: CA15-3 (Cancer Antigen15-3), CA19-9 (Cancer Antigen19-9), CA125 (Cancer Antigen125), PSA (Prostate-Specific-Antigen), HCG (Beta-Human Chorionic Gonadotropin)

សេវាបង្ការដែលបានកំណត់នេះត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឬវិទ្យាស្ថានសាធារណៈ។

សេវានេះមិនត្រូវបានទូទាត់សងវិញ ចំពោះការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលឯកជន ឬមន្ទីរពិសោធន៍ឯកជនក្នុង ឬក្រៅប្រទេសឡើយ លើកលែងមានការអនុញ្ញាតពីប.ស.ស។ ប.ស.ស ត្រូវទទួលបន្ទុក និងកំណត់យន្តការទូទាត់ថ្លៃសេវាបង្ការសុខភាពដូចដែលមានចែង។

### ៣.២.៣. លក្ខខណ្ឌទទួលបានសេវាថែទាំសុខភាព

#### ៣.២.៣.១. សេវាព្យាបាល និងថែទាំវេជ្ជសាស្រ្ត

យោងតាមប្រការ៦ នៃប្រកាសស្តីពីតារកាលិកថែទាំសុខភាព ដើម្បីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្រុត កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌមួយចំនួនរួមមាន៖

- កម្មករនិយោជិត ត្រូវតែកំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបធានារ៉ាប់រងសុខភាព។
- កម្មករនិយោជិតដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព។
- កម្មករនិយោជិត ដែលបានបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាពក្នុងរយៈពេល ០២ខែជាប់គ្នា ឬបានបង់ភាគទានយ៉ាងតិច ០៦ខែក្នុងអំឡុងពេល១២ខែចុងក្រោយ គិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព ឬមាតុភាព។

ករណីដែលសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គមបានបង់ភាគទាន ២ខែជាប់គ្នា ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទានដោយសារការបញ្ចប់កិច្ចសន្យាការងារនោះ សមាជិកមានសិទ្ធិ

ទទួលសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្ររយៈពេល ពីរខែថែមទៀតគិតចាប់ពី កាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាការងាររបស់សាមីជន។

បែបបទ និងនីតិវិធីដើម្បីទទួលបានការថែទាំវេជ្ជសាស្ត្រពីមូលដ្ឋានសុខាភិបាល គឺសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវបង្ហាញអត្តសញ្ញាណរបស់ខ្លួនដែលបានកំណត់ដោយ ប.ស.ស។ ករណីសង្គ្រោះបន្ទាន់ជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត។ បន្ទាប់មក ប.ស.ស នឹងទូទាត់សំណងសម្រាប់ការចំណាយលើការព្យាបាលសង្គ្រោះបន្ទាន់ទៅជនរងគ្រោះ ឬមន្ទីរពេទ្យដោយឈរលើមូលដ្ឋានគុណភាព និងតម្លៃរបស់មន្ទីរពេទ្យដែលមានកិច្ចព្រមព្រៀងជាមួយនឹង ប.ស.ស។ ក្រៅពីករណីសង្គ្រោះបន្ទាន់ ប.ស.ស មិនទូទាត់សំណងឡើយចំពោះសមាជិកណាដែលទៅព្យាបាលជម្ងឺនៅមូលដ្ឋានសុខាភិបាល ដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។

#### ៣.២.៣.២. លក្ខខណ្ឌទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ

ដើម្បីទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- ប្រាក់បំណាច់ប្រចាំថ្ងៃជាប្រាក់ដែលផ្តល់ជូនសម្រាប់រយៈពេលអាក់ខានការងារដោយសារការធ្លាក់ខ្លួនមានជម្ងឺ គ្រោះថ្នាក់ និងលំហែមាតុភាព
- បានបំពេញលក្ខខណ្ឌដូចដែលមានចែងក្នុងលក្ខខណ្ឌតារកាលិកសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
- ត្រូវសុំច្បាប់ឈប់សម្រាកពីនិយោជកតាមទម្រង់ដែលកំណត់ដោយ ប.ស.ស
- បានបង់ភាគទានយ៉ាងតិច០៩ខែ ជាប់គ្នាចំពោះប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការសម្រាកមាតុភាព។

### ៣.២.៤. សិទ្ធិទទួលបានសេវាថែទាំសុខភាព

សមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គម ដែលបានបំពេញលក្ខខណ្ឌក្នុងការទទួលបានសេវាថែទាំសុខភាពរួចរាល់ នឹងមានសិទ្ធិទទួលបានការព្យាបាលដោយឥតគិតថ្លៃ នៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង ជាមួយបេឡាជាតិរបបសន្តិសុខសង្គម ក្នុងរយៈពេលមិនលើសពី ១៨០ថ្ងៃក្នុងកំឡុងពេល ១២ខែគិតទាំងរយៈពេលព្យាបាលដោយសម្រាកក្នុងមន្ទីរពេទ្យ និងមិនសម្រាកក្នុងមន្ទីរពេទ្យ។

ប្រាក់បំណាច់ប្រចាំថ្ងៃចំនួន ៧០%នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជនសម្រាប់រយៈពេលអាក់ខានការងារ ដោយសារការសម្រាកព្យាបាលថែទាំជម្ងឺ ឬរបួសតាមវេជ្ជបញ្ជាមាន

រយៈពេលជាប់គ្នា មិនលើសពី០៧ថ្ងៃ។ កម្មករនិយោជិត នឹងទទួលបានប្រាក់ឈ្នួលពីនិយោជក ក្នុងករណីដែលអាក់ខានធ្វើការងារ ដោយសារឈប់សម្រាកព្យាបាលថៃទាំជម្ងឺ ឬរបួសតាមវេជ្ជបញ្ជាដែលមានរយៈពេលជាប់គ្នាត្រឹម ០៧ថ្ងៃចុះ។ លើសពីនេះទៀត ពួកគេនឹងទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ៧០%នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជន សម្រាប់រយៈពេល ៩០ថ្ងៃនៃការឈប់សម្រាកមុន និងក្រោយពេលសម្រាលកូន[78]។

កម្មករនិយោជិត មានសិទ្ធិទទួលបានសេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ និងបញ្ជូនសព។ សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលប៉ុណ្ណោះ។ ចំពោះសេវាបញ្ជូនអ្នកជម្ងឺធ្ងន់ធ្ងរ ដែលមិនអាចព្យាបាលឲ្យជា ឬសពត្រូវផ្តល់ជូនទៅតាមតម្លៃមូលដ្ឋានសុខាភិបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម[79]។

### ៣.២.៥. ជម្ងឺរ៉ាំរ៉ៃ

តាវកាលិកជម្ងឺរ៉ាំរ៉ៃធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាល និងត្រូវប្រើប្រាស់តែឱសថសារវន្តតែប៉ុណ្ណោះ[80]។ ចំពោះឱសថក្រៅពីបញ្ជីឱសថសារវន្ត គឺជាបន្ទុកផ្ទាល់របស់អ្នកជម្ងឺ។ ប្រភេទជម្ងឺរ៉ាំរ៉ៃដែលបានកំណត់ដោយបេឡាជាតិរបបសន្តិសុខសង្គមរួមមាន[81]៖

- ជម្ងឺខ្សោយបេះដូង
- ជម្ងឺសាច់ដុំបេះដូង
- ជម្ងឺរលាកថ្លើមប្រភេទរ៉ាំរ៉ៃ
- ជម្ងឺតម្រងនោមរ៉ាំរ៉ៃ
- ជម្ងឺក្រិនថ្លើម
- ជម្ងឺសរសៃឈាមក្រហមបេះដូង
- ជម្ងឺទឹកនោមផ្អែមប្រភេទទីមួយ និងទីពីរ
- ជម្ងឺវិបត្តិចង្វាក់បេះដូង
- ជម្ងឺក្រិនសរីរាង្គ

[78]ចំណុច៧.១ក្នុងប្រការ៧នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ស្តីពីតាវកាលិកថែទាំសុខភាព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

[79]ចំណុច៧.២ក្នុងប្រការ៧នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ស្តីពីតាវកាលិកថែទាំសុខភាព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

[80]ប្រការ៥ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ស្តីពីតាវកាលិកថែទាំសុខភាព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

[81]ប្រការ២ នៃប្រកាសលេខ២៣៨ ក.ប/ប្រ.ក ស្តីពីការកំណត់បញ្ជីជម្ងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦

- ជម្ងឺវិកលចរិត
- ជម្ងឺលុយពុល
- ជម្ងឺតាឡាសសឺមី

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកផ្តល់សេវាជម្ងឺរ៉ាំរ៉ៃ ដូចដែលបានកំណត់។

**៣.២.៦. ករណីផ្សេងៗមិនរាប់បញ្ចូលក្នុងតាវការលិកសំណង**

សមាជិកនៃ ប.ស.ស មានសិទ្ធិទទួលបានសេវាព្យាបាល និងថែទាំសុខភាពពីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ប៉ុន្តែមានសេវាមួយចំនួនមិនត្រូវបានរាប់បញ្ចូលក្នុងសេវាព្យាបាលវេជ្ជសាស្ត្ររួមមាន[82]៖

- សេវាព្យាបាលដោយមិនគិតថ្លៃដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
- ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ
- ការផ្សាំ ឬប្តូរសរីរាង្គផ្សេងៗ (ខួរឆ្អឹង តំរងនោម ថ្លើម បេះដូង និងលំពែងជាដើម)
- សេវាបង្កកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាល ឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
- ការលាងឈាម
- ការព្យាបាលមហារីកដោយសារធាតុគីមី

ប៉ុន្តែក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចបានរៀបរាប់ខាងលើនេះត្រូវបានផ្តល់ជូន។

[82] ប្រការ៤ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ស្តីពីតាវកាលិកថែទាំសុខភាព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

## ៣.៣. ការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាព

### ៣.៣.១. ការចុះកិច្ចព្រមព្រៀង

ដើម្បីឲ្យសមាជិក ប.ស.ស ទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ មូលដ្ឋានសុខាភិបាល និងបេឡាជាតិរបបសន្តិសុខសង្គមត្រូវមានកាតព្វកិច្ចចុះកិច្ចព្រមព្រៀងជាមួយគ្នាដោយស្របតាម ប្រកាសអន្តរក្រសួង លេខ២៩១ ក.ប/ប្រ.ក ស្តីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព។ កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គមដោយអនុលោមតាមទម្រង់កិច្ចព្រមព្រៀងដូចមានចែងក្នុងឧបសម្ព័ន្ធ១ សម្រាប់មជ្ឈមណ្ឌលសុខភាព ឧបសម្ព័ន្ធ២ សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ និងឧបសម្ព័ន្ធ៣ សម្រាប់មន្ទីរពេទ្យជាតិ។

មូលដ្ឋានសុខាភិបាលឯកជន អាចចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស បានលុះត្រាតែមានអាជ្ញាប័ណ្ណដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតសេវា និងគុណភាពសេវាពី ប.ស.ស។

កិច្ចព្រមព្រៀងរវាង ប.ស.ស ជាមួយនឹងមូលដ្ឋានសុខាភិបាល ត្រូវផ្អែកទៅលើសេចក្តីត្រូវការចាំបាច់ ទីតាំងភូមិសាស្ត្រ និងស្ថានភាពរបស់មូលដ្ឋានសុខាភិបាលដែលរួមមាន ហេដ្ឋារចនាសម្ព័ន្ធសមស្រប និងគ្រប់គ្រាន់ សម្រាប់ការផ្តល់សេវាសុខាភិបាលឲ្យមានគុណភាព។ មូលដ្ឋានសុខាភិបាលត្រូវមាន អគារសមរម្យ និងបរិស្ថានអនាម័យល្អ ព្រមទាំងមានឱសថ សម្ភារៈ បរិក្ខារ និងឧបករណ៍ពេទ្យ និងមធ្យោបាយចាំបាច់នានាដែលងាយស្រួលដល់ការធ្វើរោគវិនិច្ឆ័យ និងការផ្តល់សេវាព្យាបាល និងថែទាំស្របទៅតាមបទបញ្ជា និងអាជ្ញាប័ណ្ណផ្សេងៗរបស់ក្រសួងសុខាភិបាល។ បុគ្គលិកសុខាភិបាល ត្រូវមានសមត្ថភាពបច្ចេកទេស និងក្រមសីលធម៌ ព្រមទាំងមានសមត្ថភាពស្របតាមការកំណត់របស់ក្រសួងសុខាភិបាល[83]។

### ៣.៣.២. ការត្រួតពិនិត្យគុណភាពសេវា

ប.ស.ស ត្រូវត្រួតពិនិត្យ និងតាមដានគុណភាពសេវាសុខាភិបាល ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀង ការប្រើប្រាស់សេវាសុខាភិបាលរបស់សមាជិកប.ស.ស ដោយ

[83] ប្រការ៣ នៃប្រកាសអន្តរក្រសួង លេខ២៩១ ក.ប/ប្រ.ក ស្តីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

អនុវត្តយន្តការត្រួតពិនិត្យ និងការសហប្រតិបត្តិការផ្តល់ពត៌មានទៅវិញទៅមក ដើម្បីលើកកម្ពស់គុណភាពសេវាជាប្រចាំ និងតម្រង់ទិសការប្រើប្រាស់សេវារបស់សមាជិក ប.ស.ស ឲ្យកាន់តែមានប្រសិទ្ធិភាព។

ការត្រួតពិនិត្យតាមដានគុណភាពសេវាសុខាភិបាលត្រូវផ្តោតជាចម្បងលើ៖

- រចនាសម្ពន្ធ័គុណភាពសេវា
- កម្រិតផ្តល់សេវា
- បែបបទ នៃការធ្វើរោគវិនិច្ឆ័យ
- ការព្យាបាល និងការថែទាំ
- ព្រមទាំងកម្រិតនៃការពេញចិត្តចំពោះគុណភាពសេវារបស់សមាជិកប.ស.ស ដោយប្រើឧបករណ៍វាយតម្លៃគុណភាពសេវា ដែលកំណត់ដោយក្រសួងសុខាភិបាល។

ដើម្បីធានាបានគុណភាពសេវាជូនសមាជិករបស់ខ្លួន ប.ស.ស ត្រូវកំណត់ពីវិធីសាស្ត្រ និងនីតិវិធី ក្នុងការវាស់វែងពីប្រសិទ្ធិភាព នៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង[84]។

### ៣.៣.៣. ការទូទាត់ថ្លៃសេវាថែទាំសុខភាព

#### ៣.៣.៣.១. យន្តការទូទាត់ថ្លៃសេវា

យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព មានគោលបំណងដើម្បីកំណត់យន្តការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ សេវាបញ្ជូនសពសម្រាប់ផ្នែកថែទាំសុខភាពដែល ប.ស.ស ត្រូវផ្តល់ជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង ឬមូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាសង្គ្រោះបន្ទាន់។

យន្តការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រត្រូវបានកំណត់តាមវិធីសាស្ត្រពីរយ៉ាង៖

- វិធីសាស្ត្រទូទាត់ថ្លៃតាមករណី ប្រើប្រាស់សម្រាប់ទូទាត់តាមអត្រាតម្លៃថេរតាមប្រភេទករណីជម្ងឺ និងតាមកម្រិតមូលដ្ឋានសុខាភិបាលនីមួយៗដូចមានចែងក្នុងឧបសម្ពន្ធ័ទី១នៃប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

[84]ប្រការ៦នៃប្រកាសអន្តរក្រសួងលេខ២៩១ កប/ប្រកស្តីពី កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦

- វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា ត្រូវបានអនុវត្តចំពោះប្រភេទសេវាសម្រាប់ករណីពិសេស ដូចមានចែងក្នុងឧបសម្ពន្ធ័ទី២ នៃប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រកស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

វិធីសាស្ត្រទាំងពីរនេះ ត្រូវអនុវត្តសម្រាប់ផ្នែកថែទាំសុខភាព ដែលស្ថិតនៅក្នុងដែនអនុវត្តរបស់ ប.ស.ស និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា[85]។

**៣.៣.៣.២. បែបបទទូទាត់ថ្លៃសេវាថែទាំសុខភាព**

ការទូទាត់ថ្លៃសេវា ជូនមូលដ្ឋានសុខាភិបាល អាចធ្វើទៅបានលុះត្រាតែមានការកំណត់ពីលទ្ធភាពផ្តល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ កម្រិតនៃការទូទាត់ថ្លៃតាមប្រភេទករណី និងកម្រិតនៃការទូទាត់ថ្លៃតាមប្រភេទសេវាដោយ ប.ស.ស។ ទោះជាយ៉ាងណាក៏ដោយ ការកំណត់ពីកម្រិតផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលនេះ មិនត្រូវទាបជាងកម្រិតកំណត់ដោយក្រសួងសុខាភិបាលឡើយ។

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវទូទាត់ថ្លៃសេវាជូនមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងតាមរយៈប្រពន្ធ័ធនាគារ។ ការទូទាត់នេះត្រូវធ្វើឡើងទៅតាមកាលវិភាគ បែបបទ និងនីតិវិធីដូចមានចែងក្នុងឧបសម្ពន្ធ័នីមួយៗនៃប្រកាសលេខ២៩១កប/ប្រក ប្រកាសអន្តរស្តីពី កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាពចុះថ្ងៃ២៥ ខែកក្កដា ឆ្នាំ២០១៦។

**៣.៣.៣.៣. ការបដិសេធទូទាត់ថ្លៃសេវា**

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចទូទាត់ថ្លៃសេវា ជូលដល់មូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង។ ប៉ុន្តែ ប.ស.ស ក៏មានសិទ្ធិបដិសេធទូទាត់ថ្លៃសេវាទាំងស្រុង ឬមួយផ្នែកនៃថ្លៃសេវាក្នុងករណីដូចជា៖

- សេវាសុខាភិបាលដែលផ្តល់ឲ្យលើសពីតម្រូវការចាំបាច់ នៃបញ្ហាសុខភាព ឬលក្ខខណ្ឌជម្ងឺ។
- អន្តរាគមន៍ ឬបែបបទនៃការធ្វើរោគវិនិច្ឆ័យ ការផ្តល់ការព្យាបាល និងថែទាំមិនស្របតាមពិធីសារនៃការព្យាបាល ឬគោលការណ៍ណែនាំបច្ចេកទេសរបស់ក្រសួងសុខាភិបាល។

---

[85]ប្រការ៣ នៃប្រកាសលេខ១៧៣កប/ប្រក ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦

- ការប្រើប្រាស់ឱសថដែលមានគុណភាពអន់ ឬគ្មានប្រភពច្បាស់លាស់ ឬគ្មានអជ្ញាប័ណ្ណទទួលស្គាល់ត្រឹមត្រូវដោយក្រសួងសុខាភិបាល និងការចេញវេជ្ជបញ្ជាមិនត្រឹមត្រូវ។
- ការក្លែងបន្លំឯកសារ ឬផ្តល់ពត៌មានមិនពិត ដែលជាយន្តការសម្រាប់ការទូទាត់ថ្លៃសេវា។
- ការទទួលយកនូវការអនុវត្តតាមបទដ្ឋាន និងការព្យាបាលដែលមានគម្លាតខុសគ្នាទាំងស្រុង។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយប្រធានបទខាងលើរួចមកយើងឃើញថា បេឡាជាតិរបបសន្តិសុខសង្គមដែលបានបង្កើតឡើងនៅឆ្នាំ២០០៨ បានផ្តល់អត្ថប្រយោជន៍ជាច្រើន និងដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមការងាររបស់កម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងជួយសម្រួល និងផ្តល់លក្ខណៈប្រសើរជាច្រើនដល់និយោជក បន្ទាប់ពីសហគ្រាស គ្រឹះស្ថានរបស់ខ្លួនបានចុះបញ្ជិកា។ លើសពីនេះទៅទៀត បេឡាជាតិរបបសន្តិសុខសង្គម បានផ្តល់សេវាផ្នែកសន្តិសុខសង្គមក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជម្ងឺ និងមាតុភាពជាដើម។ ដោយអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់ខ្លួន បេឡាជាតិរបបសន្តិសុខសង្គមបានដាក់ឲ្យដំណើរការជំហានបន្ទាប់ផ្នែកថែទាំសុខភាពនៅឆ្នាំ២០១៦ បន្ទាប់ពីទទួលបានលទ្ធផលល្អប្រសើរពីការអនុវត្តជំហានដំបូងរបស់ខ្លួនទាក់ទងនឹងផ្នែកហានិភ័យការងារ ដែលទាំងនេះគឺជាចំណុចវិជ្ជមានមួយដែលសបញ្ជាក់ពីការវិវត្តរបស់ប្រទេសកម្ពុជា ទាក់ទងទៅលើប្រព័ន្ធនៃការធានារ៉ាប់រងសង្គម។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តនេះមានភាពរលូនលុះត្រាតែមានកត្តាចូលរួមជាច្រើន ដូចជាការដាក់ចេញលិខិតបទដ្ឋានគតិយុត្តិដែលពាក់ពន្ធ័នឹងរបបធានារ៉ាប់រងសង្គម ការចូលរួមសហការពីកម្មករនិយោជិត ក៏ដូចជានិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងការខិតខំប្រឹងប្រែង យកចិត្តទុកដាក់ពីបេឡាជាតិរបបសន្តិសុខសង្គម។ ជាក់ស្តែង យើងសង្កេតឃើញថារាជរដ្ឋាភិបាលរួមនិងក្រសួងដែលពាក់ពន្ធ័បានធ្វើការដាក់ចេញលិខិតបទដ្ឋានគតិយុត្ត ដូចជាអនុក្រឹត្យ ប្រកាស សេចក្តីណែនាំ សេចក្តីជូនដំណឹងនានា ពាក់ព័ន្ធនឹងរបបធានារ៉ាប់រងសង្គម ដើម្បីមានភាពងាយស្រួល និងមានលក្ខណៈច្បាស់លាស់ដល់អ្នកអនុវត្ត។ ចំណែកកម្មករនិយោជិត ក៏ដូចជា និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានមានកាតព្វកិច្ចធ្វើតាមនីតិវិធីនានាដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ឧទាហរណ៍ដូចជា ការចុះបញ្ជិកា ការបង់ភាគទាន ការជូនដំណឹងពីគ្រោះថ្នាក់ការងារ ការទទួលបានតាវកាលិកជាដើម។ បេឡាជាតិរបបសន្តិសុខសង្គមមានកាតព្វកិច្ចអនុវត្តការងាររបស់ខ្លួន និងផ្តល់តាវកាលិក ប្រកបដោយប្រសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា។

ជាក់ស្តែងផ្នែកធានារ៉ាប់រងហានិភ័យការងារ ដែលតម្រូវឲ្យចុះបញ្ជិកា បង់ភាគទានតាមការកំណត់ដូចដែលមានចែងក្នុងអនុក្រឹត្យ ឬប្រកាស និងផ្តល់តាវកាលិកជាសេវាជូនកម្មករនិយោជិតនៅពេលជួបគ្រោះថ្នាក់ការងារ ដូចជាសេវាព្យាបាល និងថែទាំសុខភាព ប្រាក់វិភាជន៍បូជាសពប្រាក់ឧត្តរជីវីជាដើម។ ដោយឡែកនៅឆ្នាំ ២០១៦ បេឡាជាតិរបបសន្តិសុខសង្គមបានពង្រីកវិសាលភាពរបស់ខ្លួនគ្របដណ្តប់នៅទូទាំងប្រទេស ចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានបានចំនួន ៨.៧៣១

សហគ្រាស មានកម្មករនិយោជិតចំនួន ១.១៣៦.២៧១នាក់ ចុះកិច្ចព្រមព្រៀងប្រើប្រាស់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រជាមួយមូលដ្ឋានសុខាភិបាលចំនួន៩៧។ ម្យ៉ាងវិញទៀតជំហានទី២របស់បេឡាជាតិរបបសន្តិសុខសង្គម ក៏តម្រូវឲ្យបង់ភាគទាន ចុះបញ្ជិកាស្រដៀងនិងផ្នែកហានិភ័យការងារដែរ។ ផ្នែកថែទាំសុខភាពបង្កើតឡើងដើម្បីឲ្យកម្មករនិយោជិត ទទួលបានការថែទាំ និងការព្យាបាលសុខភាព ការពារប្រឆាំង និងការប្រចុយប្រថាននៃការចំនាយលើមហន្តរាយផ្នែកសុខភាព និងការខាតបង់ប្រាក់ចំណូលនៅពេលមានជម្ងឺ។ ជាក់ស្តែងមានសមាជិក ៦០០.៨៣១នាក់បានចុះបញ្ជិកា សមាជិកដែលបានទៅប្រើប្រាស់សេវាចំនួន ១៦.០៦៣ នាក់។

បេឡាជាតិរបបសន្តិសុខសង្គម មានការអភិវឌ្ឍបន្តិចម្តងៗ និងសមិទ្ធិផលការងារល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំគួរឲ្យកត់សម្គាល់ ប៉ុន្តែទន្ទឹមនឹងនេះក៏មានចំនុចអវិជ្ជមានមួយចំនួនផងដែរ ដែលទាក់ទងនិងការអនុវត្តកាតព្វកិច្ចមិនទាន់បានល្អប្រសើរពីសំណាក់ និយោជក និងកម្មករនិយោជិត គុណភាពសេវាព្យាបាលថែទាំវេជ្ជសាស្ត្រនៅមានកម្រិត និងបញ្ហារបស់បេឡាជាតិរបបសន្តិសុខសង្គម។ យើងសង្កេតឃើញថាចំនួនគ្រោះថ្នាក់ការងារនៅតែកើនឡើង ហើយការយល់ដឹងរបស់កម្មករនិយោជិតទាក់ទងសុខភាព និងគ្រោះថ្នាក់ការងារក៏នៅមានកំរិត។

ជាអនុសាសន៍ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងទាក់ទងនឹង ការចុះបញ្ជិកា ការបង់ភាគទាន និងការផ្តល់តាវកាលិក ហានិភ័យការងារ និងថែទាំសុខភាព ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាបេឡាជាតិរបបសន្តិសុខសង្គមត្រូវពង្រឹង និងពង្រីកសមត្ថកិច្ចរបស់ខ្លួន រួមទាំងផ្តល់សេវាបន្ថែមដើម្បីជួយដល់កម្មករនិយោជិតនៅកម្ពុជា រួមទាំងផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការចូលជាសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គមកាន់តែទូលំទូលាយជាងមុន។ ដើម្បីឲ្យរបបធានារ៉ាប់រងសង្គមមានលក្ខណៈល្អប្រសើរ គឺទាមទារឲ្យមានការជួយជ្រោមជ្រែង និងគាំទ្រសហការបន្ថែមទៀតពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍ ទាក់ទងនឹងការអភិវឌ្ឍសន្តិសុខសង្គមនៅកម្ពុជា ត្រូវមានការចូលរួមយ៉ាងសកម្មក្នុងការចាត់វិធានការអប់រំ ផ្សព្វផ្សាយដើម្បីបង្ការ ទប់ស្កាត់គ្រោះថ្នាក់ការងារ និងបញ្ហាសុខភាពកម្មករនិយោជិតឲ្យនៅកំរិតទាបបំផុត។ លើសពីនេះកម្មករនិយោជិតខ្លួនឯងផ្ទាល់ត្រូវមានការយល់ដឹងចំពោះបញ្ហាសុខភាព និងប្រុងប្រយត្ន័ខ្ពស់ក្នុងការបំពេញការងារ ជាពិសេសការធ្វើដំណើរទៅមក ជៀសវាងគ្រោះថ្នាក់ផ្សេងៗដែលធ្វើឲ្យខាតបង់ប្រយោជន៍ជាច្រើន។

ជាអវសានកថានៃសារណានេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាបេឡាជាតិរបបសន្តិសុខសង្គមជាស្ថាប័នមួយដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់ប្រជាពលរដ្ឋខ្មែរ ក្នុងការប្រឆាំងតទល់ នឹងភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម។ ជាចុងក្រោយយើងសង្ឃឹមថារបបធានារ៉ាប់រងហានិភ័យ

ការងារ និងរបបថែទាំសុខភាព មានការប្រសើរឡើងថែមទៀត និងជួយកម្មករនិយោជិត ឬសិទ្ធិវន្ត បន្តទៀត និងនាពេលខាងមុខដ៏ខ្លី យើងរំពឹងថាជំហានបន្ទាប់របស់បេឡាជាតិរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន នឹងមានវត្តមានដាក់ឲ្យដំណើរការក្នុងសង្គមកម្ពុជា៕

# ឯកសារយោង

# ឯកសារយោង

**រដ្ឋធម្មនុញ្ញ**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

**ច្បាប់ និងបទដ្ឋានគតិយុត្ត**

- ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
- ច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧
- ច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០២
- អនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧
- អនុក្រឹត្យលេខ០១ អនក្រ.បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦
- ប្រកាសលេខ០២១/០៨ កប-ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨
- ប្រកាសលេខ០២២/០៨ កប-ប្រក ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨
- ប្រកាសលេខ១០៨ កប-ប្រក ស្តីពីអត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
- ប្រកាសលេខ១០៩ កប-ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
- ប្រកាសរួមលេខ១១០ កប-ប្រក ស្តីពីការជូនដំណឹងហានិភ័យការងា ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
- ប្រកាសលេខ១៤០ កប-ប្រក ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ នៃប្រកាសលេខ១០៩ កប-ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

- ប្រកាសលេខ១៩០ កប-ប្រក ស្តីពីការកែសម្រួលប្រការ៧ និងប្រការ៩ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ នៃប្រកាសលេខ១០៩ កប-ប្រក ស្តីពីតារកាលិកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
- ប្រកាសលេខ២៨៥ កប-ប្រក ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នៃប្រកាសលេខ០២១ កប-ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨
- ប្រកាសលេខ២៩៤ កប-ប្រក ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ នៃប្រកាសលេខ១០៨ កប-ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨
- ប្រកាសលេខ០៩៣/១៦ កប/ប្រ.ក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទ នៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ ២០១៦
- ប្រកាសលេខ ១០៩ កប/ប្រ.ក ស្តីពីតារកាលិកថែទាំសុខភាពចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ ២០១៦
- ប្រកាសលេខ១៧៣ កប/ប្រ.ក ប្រកាសអន្តរក្រសួងស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦
- ប្រកាសលេខ២២០ កប/ប្រ.ក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទាន សម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦
- ប្រកាសលេខ២៣៨ កប/ប្រ.ក ស្តីពីការកំណត់បញ្ជីជម្ងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦
- ប្រកាសលេខ២៩១ កប/ប្រ.ក ប្រកាសអន្តរក្រសួងស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦
- ប្រកាសលេខ០៤៩/១៧ កប/ប្រ.ក ស្តីពីការដាក់បញ្ចូលនៃសេវាបង្ការសុខភាពនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧
- សេចក្តីជូនដំណឹងលេខ០១/០៩ របស់បេឡាជាតិរបបសន្តិសុខសង្គម
- សេចក្តីជូនដំណឹងលេខ១១២ បសសសជណ ស្តីពីនីតិវិធីនៃការបង់ភាគទាន និងការដោះស្រាយហានិភ័យការងារ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨

## ឯកសារផ្សេងៗ

- វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ រៀបរៀងដោយសមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ បោះពុម្ពលើកទី២ ឆ្នាំ២០១៦
- សៀវភៅនីតិការងារ និងនិរភ័យសង្គម រៀបរៀងដោយលោកសាស្ត្រាចារ្យហេង លីណា
- របាយការណ៍ ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត
- គេហទំព័ររបស់បេឡាជាតិរបបសន្តិសុខសង្គម http://www.nssf.gov.kh/default (ចូលមើលថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៧)

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតយន្តការផ្តល់ជូនសមាជិក ប.ស.ស នូវសេវាបង្ការសុខភាព និងតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងសហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់នៃកម្មករនិយោជិតដែលជាសមាជិក ប.ស.ស និងសមាជិក ប.ស.ស ដែលកំពុងទទួលបានប្រាក់ធនលាភ ដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងឧត្តរជីវី។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ថែទាំសុខភាព** សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គម ដែលត្រូវផ្តល់តាវកាលិក សេវាបង្ការសុខភាព តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។
- **តាវកាលិក** សំដៅដល់ការផ្តល់សេវាបង្ការសុខភាព សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនៅពេលសម្រាកព្យាបាលជំងឺឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងមាតុភាព។
- **សហព័ទ្ធ** សំដៅដល់ ប្រពន្ធ ឬប្តី ដែលនៅមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។
- **ឧត្តរជីវី** សំដៅដល់អ្នកនៅរស់មានជីវិត ជាប្រពន្ធ ឬ ប្តី និងកូន នៅក្នុងបន្ទុកផ្ទាល់នៃសាមីជនដែលជាសមាជិកប.ស.ស ក្រោយពីទទួលមរណភាពដោយហានិភ័យការងារ។

## ជំពូកទី ២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាជាន់ខ្ពស់មួយ ដែលជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ត្រូវបង្កើតឡើងដោយអនុក្រឹត្យដោយឡែក ដើម្បីគ្រប់គ្រងធ្វើអធិការកិច្ច តាមដាន ត្រួតពិនិត្យរាល់ការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស និងកំណត់គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម។

## ជំពូកទី ៣
## ភាគទាន គាវកាលិក និងប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

### ផ្នែកទី ១
### ភាគទានផ្នែកថែទាំសុខភាព

**មាត្រា ៧.-**

និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់ ប.ស.ស ។ ផ្នែកនៃភាគទានដែលជាបន្ទុករបស់កម្មករនិយោជិត មិនត្រូវលើសពីផ្នែកនៃភាគទានដែលជាបន្ទុករបស់និយោជកឡើយ។

អត្រាភាគទានផ្នែកថែទាំសុខភាព បែបបទ និងនីតិវិធីនៃការបង់ភាគទាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

### ផ្នែកទី ២
### គាវកាលិកផ្នែកថែទាំសុខភាព

**មាត្រា ៨.-**

គាវកាលិកផ្នែកថែទាំសុខភាព ដែលកំណត់ក្នុងអនុក្រឹត្យនេះរួមមាន ការផ្តល់សេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

ប្រភេទសេវា និងជំងឺដែលមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងគាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើពីក្រុមប្រឹក្សាភិបាល នៃ ប.ស.ស។

បែបបទ និងនីតិវិធី នៃការផ្តល់គាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

យន្តការនៃការទូទាត់ចំណាយសេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

**មាត្រា ៩.-**

ការទទួលបានគាវកាលិកថែទាំសុខភាព ត្រូវអនុលោមតាមលក្ខខណ្ឌដែលពាក់ព័ន្ធនឹងរយៈពេលធានារ៉ាប់រង និងរយៈពេលយោង ដែលលក្ខខណ្ឌទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ផ្នែកទី ៣
## ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

**មាត្រា ១០.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកថែទាំសុខភាព ត្រូវស្មើនឹងចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់តាវកាលិក ក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំចុងក្រោយ ។

## ជំពូកទី ៤
## ការទទួលស្គាល់ និងការត្រួតពិនិត្យគុណភាពសេវារបស់មូលដ្ឋានសុខាភិបាល

## ផ្នែកទី ១
## ការទទួលស្គាល់គុណភាពសេវា

**មាត្រា ១១.-**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាល ដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តស្របតាមគោលការណ៍ដែលកំណត់ដោយក្រសួងសុខាភិបាល។

## ផ្នែកទី ២
## ការត្រួតពិនិត្យគុណភាពសេវា

**មាត្រា ១២.-**

គុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន និងឃ្លាំមើលរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស។

សមាសភាព និងតួនាទីភារកិច្ចរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៥
## ដំណាក់កាលនៃការអនុវត្ត

**មាត្រា ១៣.-**

ដំណាក់កាលដំបូង ការផ្តល់សេវាថែទាំសុខភាពត្រូវអនុវត្តចំពោះតែសមាជិក ប.ស.ស និងឧត្តរជីវី។

ការផ្តល់សេវាថែទាំសុខភាពចំពោះសហព័ទ្ធ និងកូន ដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ត្រូវអនុវត្តជាបន្តបន្ទាប់អនុលោមតាមស្ថានភាព សង្គម សេដ្ឋកិច្ចជាក់ស្តែង ដែលត្រូវកំណត់ដោយប្រកាសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

# ជំពូកទី ៦
# អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ....១០៥........កប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការការពារនិរន្តរភាពការងារ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

## ប្រការ ១.- សិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ

១.១ កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជនទទួលរងនូវហានិភ័យការងារ ។

១.២ ហានិភ័យការងារ រួមមាន គ្រោះថ្នាក់ការងារ គ្រោះថ្នាក់នៅពេលធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការឆ្ពោះទៅលំនៅស្ថាន និងជំងឺវិជ្ជាជីវៈ ។

១.៣ តាវកាលិកដែលកំណត់ក្នុងប្រកាសនេះត្រូវនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

១.៤ មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ឬគ្រូពេទ្យព្យាបាល ត្រូវមានការទទួលស្គាល់ពីបេឡាជាតិរបបសន្តិសុខសង្គម ។

## ប្រការ ២.- ការជូនដំណឹងហានិភ័យការងារ

២.១ បន្ទាប់ពីបានទទួលដំណឹងពីកម្មករនិយោជិតដែលជាអ្នករងនូវហានិភ័យការងារ ឬអ្នកតំណាងអ្នករងគ្រោះ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងអំពីឧបទ្ទវហេតុនោះទៅបេឡាជាតិរបបសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ (សែសិបប្រាំបី) ម៉ោងនៃថ្ងៃធ្វើការ ។

២.២ ការជូនដំណឹងហានិភ័យការងារត្រូវធ្វើតាមទម្រង់បែបបទដែលមានកំណត់នៅក្នុងប្រកាសរួមរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល ។

## ប្រការ ៣.- ការអង្កេតហានិភ័យការងារ

៣.១ បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្តក្រុងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម ។

អធិការ ឬអភិបាលសន្តិសុខសង្គម ត្រូវធ្វើអង្កេត និងផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យ តាវកាលិកឱ្យបានយ៉ាងឆាប់បំផុត ។

៣.២ ចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំកិច្ចសហការពីអធិការ ឬអភិបាលការងារ ។ ការចំណាយសម្រាប់ផ្នែកនេះ គឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

៣.៣ ចំពោះគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងទីកន្លែង ពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែងកើតហេតុ ។

## ប្រការ ៤.- ការផ្តល់សេវាសង្គ្រោះបន្ទាន់

ក្នុងករណីដែលគ្រោះថ្នាក់កើតនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។ ក្នុងករណីដែលគ្រោះថ្នាក់នៅពេលធ្វើដំណើរ សាមីជន ឬនិយោជកអាចទាមទារការទូទាត់សង លើការចំណាយសម្រាប់ការសង្គ្រោះនេះពីបេឡាជាតិរបបសន្តិសុខសង្គម ។

## ប្រការ ៥.- ការផ្តល់សេវាថែទាំ និងព្យាបាល

៥.១ ការព្យាបាលចំពោះកម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារត្រូវតែប្រព្រឹត្តទៅនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ។

៥.២ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបាន ការពិនិត្យព្យាបាល ការសម្រាកព្យាបាល នៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ផ្អែកលើកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី ។

៥.៣ ក្នុងករណីដែល គ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬ សំភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំមានចែងនៅក្នុងកិច្ចព្រមព្រៀង បេឡាជាតិរបបសន្តិសុខសង្គមអាចទូទាត់សងទៅជនរងគ្រោះ ឬអ្នកតំណាងវិញបាន លុះណាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ ។

៥.៤ នាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំបញ្ជីមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលមានលក្ខណៈសម្បត្តិសមស្របតាមបទដ្ឋានបច្ចេកទេសវេជ្ជសាស្ត្រ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃបេឡា

ជាតិរបបសន្តិសុខសង្គមអនុម័តយល់ព្រម ។

## ប្រការ ៦.- ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ

៦.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនកាលបរិច្ឆេទនៃគ្រោះថ្នាក់ ។ ប្រាក់ឈ្នួលជាប់ភាគទាន ត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុង**ឧបសម្ព័ន្ធ ១** នៃប្រកាសនេះ ។

៦.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យមដូចមានចែងក្នុងចំណុច ៦.១ នឹង ៣០ (សាមសិប) ថ្ងៃ ។

៦.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គមប៉ុណ្ណោះ ។

## ប្រការ ៧.-ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

៧.១ រយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅ:

- រយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល
- រយៈពេលនៃការសម្រាកក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា ។

៧.២ ក្នុងរយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខ័ណ្ឌ ៧.១ ខាងលើ កម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារមានសិទ្ធិទទួលបានតាវកាលិកពីបេឡាជាតិរបបសន្តិសុខសង្គម ដូចតទៅ:

- ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ក្នុងករណី ដែលស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរតម្រូវឱ្យមានអ្នកនៅចាំថែទាំ តាមសំណើសុំរបស់គ្រូពេទ្យព្យាបាល ។

៧.៣ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវផ្តល់ចំពោះតែហានិភ័យការងារ ដែលតម្រូវឱ្យមានការសម្រាកព្យាបាលលើសពី ០៤(បួន) ថ្ងៃឡើងទៅ ។

៧.៤ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ត្រូវស្មើនឹង ៥០ (ហាសិប) ភាគរយនៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ ។

៧.៥ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន អាចផ្តល់ជូនជនរងគ្រោះដោយហានិភ័យការងារ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ (មួយរយប៉ែតសិប) ថ្ងៃ។

## ប្រការ ៨.- តាវភាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍

៨.១ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ។ ប្រាក់វិភាជន៍នេះត្រូវផ្តល់ជូនអ្នករងគ្រោះតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម:

**វបក = បឈម x ៧០% x កបក x ២០%មតប**

- **វបក:** វិភាជន៍បាត់បង់សមត្ថភាពការងារ
- **បឈម:** ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- **កបក:** កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- **មតប:** មេគុណតម្លៃបច្ចុប្បន្ន

៨.២ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០ ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ។ប្រាក់ធនលាភសរុបសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម:

**ធល = បឈម x ៧០ % x [កបក – ១/៥ កបក] x មតប**

- **ធល:** ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

៨.៣ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារអ្នករងគ្រោះឡើងវិញក្នុងរយៈពេល ១ (មួយ) ឆ្នាំយ៉ាងយូរ ។ ជនរងគ្រោះដែលទទួលបានប្រាក់ធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពតាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ។

៨.៤ កម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ។ មេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ៣** ។

## ប្រការ ៩.- ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ក្នុងកម្រិត ១០០ ភាគរយ មានសិទ្ធិទទួលបានប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាដល់ខ្លួន។ ប្រាក់បន្ថែម ...

សម្រាប់អ្នកចាំថែរក្សាត្រូវស្មើ ៥០ ( ហាសិប) ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ ។

## ប្រការ ១០.- ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព

ក្នុងករណីដែលមានការទទួលរងនូវហានិភ័យការងាររហូតបណ្តាលឱ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ១.០០០.០០០ ( មួយលាន) រៀល ។ ប្រាក់វិភាជន៍នេះ ត្រូវតែផ្តល់ជូនទៅជន ដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ ។

## ប្រការ ១១.- តាវកាលិកឧត្តរជីវី

១១.១ ឧត្តរជីវីនៃជនរងគ្រោះដោយហានិភ័យការងារដូចមានចែងនៅក្នុងមាត្រា ៣៤ នៃអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី ។

១១.២ តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះ តាមអត្រាដូចខាងក្រោម:

ក. ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក

- ប្រពន្ធ ឬប្តី = ៣/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក= ២/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៧% បឈម

ខ. ក្នុងករណីសិទ្ធិវន្ត មានតែប្រពន្ធ ឬប្តី និង/ឬ កូន

- ប្រពន្ធ ឬប្តី = ៣/៥ x ៧០%បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០%បឈម

គ. ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

ឃ. ក្នុងករណីសិទ្ធិវន្ត មានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

ង. ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ប្រពន្ធ ឬប្តី = ២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

១១.៣ សិទ្ធិវន្ត ជាប្រពន្ធ ឬប្តីនៃជនរងគ្រោះ ត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ សិទ្ធិទទួលធនលាភចំពោះសិទ្ធិវន្តដែលជាប្រពន្ធ ឬប្តី ត្រូវបានរំលាយនៅពេលដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។ ក្នុងករណីនៃការរៀបអាពាហ៍ពិពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុត ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ ការខកខានមិនបានជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន សាមីជននឹងត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

១១.៤ សិទ្ធិវន្តជា កូនត្រូវមានស្ថានភាពស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងចំណុច ៣៤.១ ខ មាត្រា ៣៤ នៃអនុក្រឹត្យលេខ១៦ អនក្រ/បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧។

១១.៥ សិទ្ធិទទួលធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព។

## ប្រការ ១២.- សេវាបុនស្តារនីតិសម្បទា

១២.១កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

១២.២កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ប្រការ ១៣.- ការទាមទារតាវកាលិក

១៣.១ ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងព្យាបាល អាចត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះផ្ទាល់តាមទម្រង់ "**តាវកាលិកថែទាំ និងព្យាបាល** " ឬហៅថាទម្រង់ " **៣.០២** "ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៤** នៃប្រកាសនេះ។

១៣.២ ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវធ្វើដោយជនរងគ្រោះ ឬតំណាងតាមទម្រង់ "**តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន** " ឬហៅថាទម្រង់ "**៣.០៣** " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៥** នៃប្រកាសនេះ។ បែបបទ នៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវវេជ្ជបញ្ជា និងលិខិតបញ្ជាក់ពីគ្រូពេទ្យព្យាបាលផ្លូវការ។

១៣.៣ ការទាមទារតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ "**តាវកាលិកបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍** " ឬហៅថាទម្រង់

"**៣.០៤** " ដូចមានចែងក្នុង**ឧបសម្ព័ន្ធ ៦** នៃប្រកាសនេះ។ ក្នុងករណីដែល ជនរងគ្រោះមិនអាចមានសមត្ថភាព ក្នុងការទាមទារតាវកាលិកបាន ដោយសារស្ថានភាពនៃការបាត់បង់សមត្ថភាពការងារធ្ងន់ធ្ងរ ការទាមទារនេះអាចត្រូវធ្វើដោយអ្នកតំណាងជនរងគ្រោះ។ អ្នកតំណាងជនរងគ្រោះ អាចជាប្តី ប្រពន្ធ កូន ឬជន ដែលមានភារៈចិញ្ចឹមដោយផ្ទាល់ចំពោះជនរងគ្រោះ។

១៣.៤ ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬអ្នកតំណាង តាមទម្រង់ "**តាវកាលិកឧត្តរជីវី** " ឬហៅថាទម្រង់ " **៣.០៥** " និងទម្រង់ " **វិភាជន៍បូជាសព**" " ឬហៅថា ទម្រង់ "**៣.០៦** " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៧ និង ៨** នៃប្រកាសនេះ។

១៣.៥ សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល ១ ( មួយ) ឆ្នាំ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភ ត្រូវអស់សុពលភាពត្រឹមរយៈពេល ៥ ( ប្រាំ) ឆ្នាំ។

១៣.៦ ការបើកប្រាក់ធនលាភ ត្រូវធ្វើប្រចាំត្រីមាស។

## ប្រការ ១៤.- ការយល់ព្រមចំពោះការទាមទារតាវកាលិក

១៤.១ តាវកាលិកថែទាំ និងព្យាបាល ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការថែទាំនិងព្យាបាលនោះធ្វើនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

ប្រសិនបើការថែទាំ និងព្យាបាលធ្វើនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលផ្សេងក្រៅពីការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ការទូទាត់សងវិញត្រូវធ្វើតាមអត្រាតម្លៃដែលបេឡាជាតិរបបសន្តិសុខសង្គមបានកំណត់។

តារាងតម្លៃសម្រាប់ការថែទាំ និងព្យាបាល ត្រូវបានកំណត់តាមកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គម និងបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល។

១៤.២ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការទាមទារនោះស្របនឹងលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ វាក្យខ័ណ្ឌ ៧.១, ៧.២ និង ៧.៣ នៃប្រកាសនេះ។

